**គណៈកម្មាធិការប្រឆាំងទារុណកម្ម**
**សម័យប្រជុំលើកទី ៤៥**
ចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០

# ការពិនិត្យពិចារណាលើរបាយការណ៍ដែលត្រូវបានដាក់ជូនដោយរដ្ឋភាគី អនុលោមតាមមាត្រា ១៩ នៃអនុសញ្ញា

## ឯកសារមុនពេលស្តាពរដែលមិនទាន់កែសម្រួល

## សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការប្រឆាំងទារុណកម្ម

ប្រទេសកម្ពុជា

១. គណៈកម្មាធិការបានពិនិត្យពិចារណាលើរបាយការណ៍តាមពេលកំណត់លើកទី២ របស់ប្រទេសកម្ពុជា (CAT/C/KHM/2) ក្នុងកិច្ចប្រជុំលើកទី៩៦៧ និងទី៩៦៨ របស់ខ្លួន (CAT/C/SR.967 និង 968) ដែលរៀបចំឡើងកាលពីថ្ងៃទី៩ និងទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ ហើយបានអនុម័តក្នុងកិច្ចប្រជុំលើកទី៩៧៩ និងទី៩៨០ (CAT/C/SR.979 និង 980) នូវសេចក្តីសង្កេតសន្និដ្ឋានដូចខាងក្រោមនេះ៖

### ក. សេចក្តីផ្តើម

២. គណៈកម្មាធិការសូមស្វាគមន៍ការដាក់ជូនរបាយការណ៍តាមពេលកំណត់លើកទី២ របស់ប្រទេសកម្ពុជា ប៉ុន្តែគណៈកម្មាធិការមានការសោកស្តាយដែលថា ការយឺតយ៉ាវយ៉ាងយូរក្នុងការដាក់ជូនរបាយការណ៍ទាន់ពេលវេលា ធ្វើឲ្យគណៈកម្មាធិការមិនអាចធ្វើការវិភាគជាប់លាប់លើការអនុវត្តអនុសញ្ញាក្នុងរដ្ឋភាគីបានឡើយ។

៣. គណៈកម្មាធិការក៏សូមស្វាគមន៍ផងដែរចំពោះការដាក់ជូនរបាយការណ៍នេះ ដោយអនុលោមតាមនីតិវិធីធ្វើរបាយការណ៍ជម្រើសថ្មីរបស់គណៈកម្មាធិការ ដែលមានចំលើយឆ្លើយតបពីរដ្ឋភាគីទៅនឹងបញ្ជីសំណួរ ( CAT/C/ KHM/Q/2) ដែលគណៈកម្មាធិការបានរៀបចំ និងបញ្ជូនទៅរដ្ឋភាគី។ គណៈកម្មាធិការសូមកោតសរសើរដល់រដ្ឋភាគីដែលបានឯកភាពរៀបចំរបាយការណ៍ ដោយប្រើប្រាស់នីតិវិធីថ្មីនេះដែលសម្រួលដល់កិច្ចសហប្រតិបត្តិការរវាងរដ្ឋភាគី និងគណៈកម្មាធិការ។

៤. គណៈកម្មាធិការសូមគោតសរសើរចំពោះកិច្ចសន្ទនាជាមួយរដ្ឋភាគី និងព័ត៌មានផ្ទាល់មាត់បន្ថែមទៀតដែលគណៈប្រតិភូរបស់រដ្ឋភាគីបានផ្តល់ ប៉ុន្តែគណៈកម្មាធិការមានការសោកស្តាយថា សំណួរមួយចំនួនរបស់ខ្លួនមិនទាន់មានការផ្តល់ចម្លើយនៅឡើយ។

## ខ. ចំណុចវិជ្ជមាន

៥. គណៈកម្មាធិការសូមស្វាគមន៍ដល់ការផ្តល់សច្ចាប័ននៅខែមិនា ឆ្នាំ២០០៧ លើពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការធ្វើទស្សនកិច្ចត្រួតពិនិត្យមើលថ្មីៗនេះរបស់អនុគណៈកម្មាធិការបង្ការទារុណកម្ម (SPT) មកកាន់ប្រទេសកម្ពុជា ចាប់ពីថ្ងៃទី៣ ដល់ទី១១ ខែធ្នូ ឆ្នាំ២០០៩។

៦. ចាប់តាំងពីពេលពិនិត្យពិចារណាលើរបាយការណ៍បឋម មក គណៈកម្មាធិការក៏សូមស្វាគមន៍ផងដែរចំពោះការដែលរដ្ឋភាគីបានផ្តល់សច្ចាប័នទៅលើ ឬចូលជាភាគីនៃលិខិតូបករណ៍អន្តរជាតិដូចខាងក្រោម៖

ក) ពិធីសារបន្ថែមទៅលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ កាលពីខែតុលា ឆ្នាំ២០១០។

ខ) អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មដែលមានការចាត់តាំងឆ្លងដែននៅខែធ្នូ ឆ្នាំ២០០៥ និងពិធីសារទប់ស្កាត់ បង្ក្រាប និងដាក់ទោសចំពោះការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលជាពិធីសារបន្ថែមទៅលើអនុសញ្ញានៅខែកក្កដា ឆ្នាំ២០០៧។

គ) អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ នៅខែកញ្ញា ឆ្នាំ២០០៧

ឃ) ពិធីសារបន្ថែមទៅលើអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ នៅខែកក្កដា ឆ្នាំ២០០៤។

ង) លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិនៅខែមេសា ឆ្នាំ២០០២។

៧. គណៈកម្មាធិការកត់សម្គាល់ថែមទៀតពីកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់នៅថ្នាក់ជាតិក្នុងការកែទម្រង់ច្បាប់ គោលនយោបាយ និងនីតិវិធី ដើម្បីធានាឲ្យមានការការពារសិទ្ធិមនុស្សកាន់តែប្រសើរជាងមុន រួមទាំងសិទ្ធិមិនទទួលរងទារុណកម្ម និងប្រព្រឹត្តកម្ម ឬទណ្ឌកម្មឯទៀតដែល ឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ជាពិសេសការអនុម័តលើ ៖

ក) ច្បាប់ប្រឆាំងអំពើពុករលួយនៅឆ្នាំ២០១០។

ខ) ក្រមព្រហ្មទណ្ឌថ្មីនៅឆ្នាំ២០០៩។

គ) ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទនៅឆ្នាំ២០០៨។
ឃ) ក្រមនីតិវិធីព្រហ្មទណ្ឌថ្មីនៅឆ្នាំ២០០៧។
ង) ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះនៅឆ្នាំ ២០០៥ រួមទាំងការដាក់បទរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ទៅជាបទល្មើសព្រហ្មទណ្ឌ។។

៨. គណៈកម្មាធិការកត់សំគាល់ដោយពេញចិត្ត ចំពោះការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(ECCC) ដោយមានកិច្ចសហប្រតិបត្តិការជា មួយអង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិ។ គណៈកម្មាធិការសូម ស្វាគមន៍ដល់អង្គជំនុំជម្រះសាលាដំបូង ដែលបានចេញសាលក្រមក្នុងសំណុំរឿង ទី ១ របស់ខ្លួន (សំណុំរឿង ០០១) កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ និងដែលបានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿងទី ២ (សំណុំរឿង ០០២) ហើយដែលប្រជាជនទាំងឡាយជាជនរងគ្រោះពីអំពើទារុណកម្ម និងប្រព្រឹត្តកម្ម ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ បន្ថោកបន្ទាប អាចចូលរួមក្នុងដំណើរការនីតិវិធីក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី។ គណៈកម្មាធិការសូមលើកទឹកចិត្តរដ្ឋភាគីឲ្យបន្ត កិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនផងដែរ ដើម្បីនាំយកជនល្មើសបន្ថែមទៀតដែលជាប់ ពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើឃោរឃៅក្នុងរបបខ្មែរក្រហមមកកាត់ទោស (សំណុំរឿង ០០៣ និងសំណុំរឿង ០០៤)។

៩. គណៈកម្មាធិការក៏សូមស្វាគមន៍ផងដែរដល់ការបង្កើតការិយាល័យជនភៀសខ្លួននៅក្នុងនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃនៅឆ្នាំ២០០៨ ក្នុងគោលដៅការពារជនភៀសខ្លួន រាប់ទាំងជនរងគ្រោះពីអំពើទារុណកម្ម និងប្រព្រឹត្តកម្ម ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ព្រមទាំងការអនុម័តអនុក្រឹត្យនៅថ្ងៃ ទី១៧ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីនីតិវិធីក្នុងការកំណត់ឋានៈជនភៀសខ្លួន និងសិទ្ធិជ្រកកោនសម្រាប់ជនបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា ដែលនេះជាចំណុចផ្តើមនៃការបង្កើតក្របខ័ណ្ឌច្បាប់មួយ។

## គ. កម្មវត្ថុចម្បងនៃក្តីបារម្ភ និងអនុសាសន៍នានា

### ការបញ្ចូលអនុសញ្ញាទៅក្នុងច្បាប់ជាតិ

១០. គណៈកម្មាធិការសូមស្វាគមន៍ចំពោះកិច្ចធានាការពារ ដែលមាន ចែងនៅក្នុងមាត្រា ៣១នៃរដ្ឋធម្មនុញ្ញ ព្រមទាំងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៅអំឡុងខែកក្កដា ឆ្នាំ២០០៧ (សេចក្តីសម្រេចលេខ ០៩២/០០៣/ ២០០៧) ដែលថាសន្ធិសញ្ញា

អន្តរជាតិទាំងឡាយគឺជាផ្នែកមួយនៃច្បាប់ជាតិ ហើយថាតុលាការគួរពិចារណាលើបទដ្ឋាននៃសន្ធិសញ្ញានានានៅពេលធ្វើការបកស្រាយច្បាប់ និងសម្រេចលើសំណុំរឿងក្តីនានា។ ទោះជាយ៉ាងនេះក្តី គណៈកម្មាធិការមានការសោកស្តាយដែលខ្លួនមិនបានទទួលព័ត៌មាន ថាតើតុលាការក្នុងប្រទេសបានយកអនុសញ្ញានេះទៅអនុវត្តចំពោះសំណុំរឿងក្តីណាមួយហើយ ឬយ៉ាងណា ដូច្នេះហើយគណៈកម្មាធិការមានការព្រួយបារម្ភថា ក្នុងការអនុវត្តជាក់ស្តែង បទប្បញ្ញត្តិនៃអនុសញ្ញាអន្តរជាតិរួមទាំងអនុសញ្ញានេះ មិនត្រូវបានយកមកប្រើធ្វើជាសំអាងនៅចំពោះមុខ ឬត្រូវបានអនុវត្តដោយផ្ទាល់ពីសំណាក់តុលាការ សាលាជំនុំជម្រះក្តី ឬអាជ្ញាធររដ្ឋបាលជាតិរបស់រដ្ឋភាគីនោះទេ។ ក្នុងបរិបទនេះគណៈកម្មាធិការកត់សំគាល់ដោយក្តីបារម្ភដែលថា ពុំមានការដោះស្រាយចំពោះការរំលោភបំពានសិទ្ធិមនុស្ស រួមទាំងការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន។ ប្រការនេះធ្វើឲ្យសមត្ថភាពរបស់រដ្ឋភាគីចុះខ្សោយក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដែលរដ្ឋភាគីបានផ្តល់សច្ចាប័នទៅលើ រួមទាំងអនុសញ្ញានេះផងដែរ (មាត្រា ២ មាត្រា ៤ និងមាត្រា ១០)។

រដ្ឋភាគីគួរចាត់វិធានការសមស្រប ដើម្បីធានាឲ្យមានការអនុវត្តបទប្បញ្ញត្តិពេញលេញនៃអនុសញ្ញានៅក្នុងឋានានុក្រមច្បាប់ជាតិរបស់ខ្លួន។ វិធានការទាំងនោះរួមមានការបណ្តុះបណ្តាលឲ្យបានទូលំទូលាយស្តីពីបទប្បញ្ញត្តិនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ រួមទាំងអនុសញ្ញានេះសម្រាប់មន្ត្រីរាជការ មន្ត្រីប្រតិបត្តិច្បាប់ និងមន្ត្រីពាក់ព័ន្ធផ្សេងៗ ក៏ដូចជាចៅក្រម ព្រះរាជអាជ្ញា និងមេធាវីផងដែរ។ គណៈកម្មាធិការក៏ស្នើឲ្យរដ្ឋភាគីធ្វើរបាយការណ៍ បញ្ជូនត្រឡប់មកវិញស្តីពីភាពជឿនលឿនក្នុងបរិបទនេះ និងលើសេចក្តីសម្រេចរបស់ តុលាការជាតិ ឬសាលាជំរះក្តី និងអាជ្ញាធររដ្ឋបាលដោយអនុវត្តឲ្យមានប្រសិទ្ធភាពនូវសិទ្ធិទាំងឡាយ ដែលបានដំកល់ទុកក្នុងអនុសញ្ញានេះ។

## និយមន័យទារុណកម្ម និងការកំណត់អំពើទារុណកម្មឲ្យទៅជាបទល្មើសព្រហ្មទណ្ឌ

១១.គណៈកម្មាធិការកត់សម្គាល់សេចក្តីថ្លែងការណ៍របស់គណៈប្រតិភូថា រដ្ឋភាគីនិយាយយោងដល់ពាក្យ "ទារុណកម្ម" ក្នុងបរិបទទូទៅជាអំពើទាំងឡាយណាបង្កបបួសស្នាមទៅលើបុគ្គល និងកំណត់អំពើ "ទារុណកម្ម" ជាបទល្មើសព្រហ្មទណ្ឌ។ ទោះបីជាមានការកត់សម្គាល់ឃើញនូវព័ត៌មានពីរដ្ឋភាគីដែលថា ក្រមព្រហ្មទណ្ឌថ្មីកំណត់ទោសទណ្ឌដល់ការប្រព្រឹត្តបទល្មើសទារុណកម្ម កំណត់ទោសទណ្ឌដល់

ការញុះញង់ឲ្យមានការប្រព្រឹត្ត ឬកំណត់ទោសទណ្ឌដល់ការឯកភាព ឬដល់ការយល់ព្រមដោយស្ងៀមស្ងាត់ពីមន្ត្រីដែលបំពេញការងារជាផ្លូវការក៏ដោយ ក៏គណៈកម្មាធិការមានការបារម្ភថា ក្រមព្រហ្មទណ្ឌនេះមិនមានចែងនិយមន័យទារុណកម្មនោះទេ។ គណៈកម្មាធិការសោកស្តាយដែលថា រដ្ឋភាគីមិនបានផ្តល់អត្ថបទចម្លងនៃបទប្បញ្ញត្តិពាក់ព័ន្ធនឹងការកំណត់អំពើទារុណកម្មជាបទល្មើសព្រហ្មទណ្ឌ (មាត្រា ១ និងមត្រា ៤)។

រដ្ឋភាគីគួរដាក់បញ្ចូលនិយមន័យទារុណកម្មទៅក្នុងរដ្ឋធម្មនុញ្ញ ក្រមព្រហ្មទណ្ឌ ឬច្បាប់ពាក់ព័ន្ធផ្សេងៗ រួមទាំងធាតុផ្សំទាំងអស់នៃទារុណកម្ម ដែលបានកំណត់ក្នុងអនុសញ្ញា។ ការដាក់បញ្ចូលនេះនឹងបង្ហាញពីការទទួលស្គាល់យ៉ាងពិតប្រាកដ និងមានសារៈសំខាន់ថា ទារុណកម្មគឺជាបទឧក្រិដ្ឋធ្ងន់ធ្ងរ រំលោភបំពានសិទ្ធិមនុស្ស និងប្រយុទ្ធប្រឆាំងនឹងនិទ្ទណ្ឌភាព។ តាមរយៈការកំណត់ឈ្មោះ និងកំណត់និយមន័យបទល្មើសទារុណកម្ម ស្របតាមមាត្រា ១ និងមាត្រា ៤ នៃអនុសញ្ញា និងភាពខុសគ្នាពីបទល្មើសដទៃទៀត គណៈកម្មាធិការយល់ឃើញថា រដ្ឋភាគីនឹងជំរុញគោលដៅរួមនៃអនុសញ្ញាដោយផ្ទាល់ដើម្បីទប់ស្កាត់ទារុណកម្មក្នុងចំណោមអំពើផ្សេងៗ ដោយក្រើនរំលឹកមនុស្សគ្រប់រូប រួមទាំងជនល្មើស ជនរងគ្រោះ និងសាធារណជនឲ្យបានដឹងអំពីភាពធ្ងន់ធ្ងរពិសេសនៃបទល្មើសទារុណកម្ម និងតាមរយៈការធ្វើឲ្យប្រសើរឡើងនូវការហាមប្រាម ដែលមានអនុភាពរាងចាល និងញញើតចំពោះបទល្មើសទារុណកម្មនេះ។ គណៈកម្មាធិការក៏ស្នើរដ្ឋភាគីផងដែរឲ្យផ្តល់ជាបន្ទាន់ នូវអត្ថបទក្រមព្រហ្មទណ្ឌថ្មីតាមសំណើក្នុងអំឡុងពេលពិភាក្សា។

## អំពើពុករលួយ

១២.គណៈកម្មាធិការមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះរបាយការណ៍នានាស្តីពីអំពើពុករលួយដែលរីករាលដាល និងជាលក្ខណៈប្រព័ន្ធនៅទូទាំងប្រទេស។ គណៈកម្មាធិការយល់ឃើញថា នីតិរដ្ឋគឺជាមូលដ្ឋានគ្រឹះសំរាប់ការពារសិទ្ធិដែលមានចែងក្នុងអនុសញ្ញា ហើយថ្វីបើមានការស្វាគមន៍ដល់ច្បាប់ប្រឆាំងអំពើពុករលួយថ្មី និងវិធានការផ្សេងៗទៀតដែលអនុវត្តដោយរដ្ឋភាគីក៏ដោយ ក៏គណៈកម្មាធិការមានការបារម្ភចំពោះរបាយការណ៍នានាទាក់ទងនឹងការជ្រៀតជ្រែកនយោបាយ និងអំពើពុករលួយ ដែលប៉ះពាល់ដល់ស្ថាប័នតុលាការ និងដំណើរការប្រព្រឹត្តទៅនៃការផ្តល់សេវាសាធារណៈមួយចំនួន រួមមានសេវាប្រតិបត្តិច្បាប់របស់នគរបាល និងសេវាប្រតិបត្តិច្បាប់ផ្សេងទៀត។ ក្នុងបរិបទនេះ គណៈកម្មាធិការមានក្តីបារម្ភចំពោះរបាយ

ការណ៍ដែលថា មន្ត្រីនគរបាលត្រូវបានដំឡើងឋានៈដោយសារតែការតាមចាប់កំហុសប្រជាពលរដ្ឋ និងនាំខ្លួនពួកគេមកឲ្យតុលាការផ្តន្ទាទោស និងថាស្ថានីយនគរបាលត្រូវបានផ្តល់រង្វាន់លើកទឹកចិត្តពិសេស ដោយសារតែការតាមចាប់កំហុសប្រជាពលរដ្ឋ និងនាំខ្លួនពួកគេមកឲ្យតុលាការផ្តន្ទាទោស ដែលមានន័យស្មើនឹងប្រព័ន្ធលើកទឹកចិត្តមួយ ព្រមទាំងរបាយការណ៍ដែលថា មន្ត្រីនគរបាលទទួលកម្រៃលើកទឹកចិត្តជាទឹកប្រាក់ពីការរៀបចំក្រៅផ្លូវការ ឬការដោះស្រាយក្រៅប្រព័ន្ធតុលាការ។ គណៈកម្មាធិការក៏មានក្តីបារម្ភថា អង្គភាពប្រឆាំងអំពើពុករលួយដែលបង្កើតឡើងក្រោមច្បាប់ប្រឆាំងអំពើពុករលួយថ្មី មិនទាន់បានចាត់វិធានការប្រឆាំងនឹងជនល្មើស ដែលត្រូវចោទប្រកាន់ពីបទពុករលួយ ហើយក៏មិនទាន់មានដំណើរការពេញលេញនៅឡើយ (មាត្រា ២ មាត្រា ១០ និងមាត្រា ១២)។

រដ្ឋភាគីគួរចាត់វិធានការជាបន្ទាន់ និងភ្លាមៗដើម្បីលុបបំបាត់អំពើពុករលួយនៅទូទាំងប្រទេស ដែលជាឧបសគ្គមួយក្នុងចំណោមឧបសគ្គដ៏ធ្ងន់ធ្ងរបំផុតទាំងឡាយដល់នីតិរដ្ឋ និងដល់ការអនុវត្តអនុសញ្ញា។ វិធានការទាំងនេះរួមមានការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយឲ្យមានប្រសិទ្ធភាព និងការដាក់ឲ្យដំណើរការនូវអង្គភាពប្រឆាំងអំពើពុករលួយឲ្យបានឆាប់រហ័ស ដែលត្រូវមានសមាជិកឯករាជ្យនានា។ រដ្ឋភាគីគួរបង្កើនសមត្ថភាពរបស់ខ្លួនក្នុងការស៊ើបអង្កេត និងជំនុំជម្រះសំណុំរឿងអំពើពុករលួយផងដែរ។ រដ្ឋភាគីគួរបង្កើតកម្មវិធីការពារសាក្សី និងអ្នករិះគន់ឥតសំចៃមាត់ដើម្បីជួយធានាដល់ការរក្សាការសម្ងាត់ និងការពារអ្នកដែលចេញមុខដាក់ពាក្យបណ្តឹងពីបទពុករលួយ ហើយធានាឲ្យមានការបែងចែកថវិកាគ្រប់គ្រាន់ សម្រាប់បំពេញមុខងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាព។ លើសពីនេះ រដ្ឋភាគីគួររៀបចំកម្មវិធីបណ្តុះបណ្តាល និងកសាងសមត្ថភាពដល់មន្ត្រីនគរបាល និងមន្ត្រីប្រតិបត្តិច្បាប់ ព្រះរាជអាជ្ញា និងចៅក្រម ស្តីពីការអនុវត្តយ៉ាងតឹងរ៉ឹងនូវច្បាប់ប្រឆាំងអំពើពុករលួយ ព្រមទាំងក្រមសីលធម៌វិជ្ជាជីវៈពាក់ព័ន្ធ និងអនុម័តយន្តការដែលមានប្រសិទ្ធភាព ដើម្បីធានាឲ្យមានតម្លាភាពក្នុងការប្រព្រឹត្តទៅរបស់មន្ត្រីសាធារណៈ ទាំងនៅក្នុងផ្នែកខ្លឹមសារច្បាប់ និងទាំងការអនុវត្តការងារជាក់ស្តែង។ គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពដែលទទួលបានជោគជ័យ និងការលំបាកទាំងឡាយដែលជួបប្រទះក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។ គណៈកម្មាធិការសូមស្នើឲ្យរដ្ឋភាគីផ្តល់ព័ត៌មានស្តីពីចំនួនមន្ត្រី រួមទាំងមន្ត្រីជាន់ខ្ពស់ដែលត្រូវបានជំនុំជម្រះ និងដាក់ទោសពីបទប្រព្រឹត្តអំពើពុករលួយ។

ឯករាជ្យភាពរបស់តុលាការ

១៣.គណៈកម្មាធិការបញ្ជាក់សាជាថ្មីម្តងទៀតពីក្តីព្រួយបារម្ភរបស់ខ្លួនចំពោះការខ្វះឯករាជ្យភាព និងប្រសិទ្ធភាពរបស់តុលាការ រួមទាំងប្រព័ន្ធយុត្តិធម៌ផ្នែកព្រហ្មទណ្ឌ ដែលរារាំងដល់ការទទួលបានពេញលេញនូវសិទ្ធិមនុស្ស ដូចជាការហាមប្រាមទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។ គណៈកម្មាធិការមានការព្រួយបារម្ភផងដែរដែលថា ច្បាប់ជាមូលដ្ឋានមួយចំនួនសម្រាប់កំណែទម្រង់ប្រព័ន្ធតុលាការ មិនទាន់បានអនុម័តនៅឡើយ។ គណៈកម្មាធិការក៏មានក្តីព្រួយបារម្ភបន្ថែមទៀត លើការខ្វះខាតឯករាជ្យភាពរបស់គណៈមេធាវី ការកំណត់ចំនួនសមាជិកមេធាវីនៅក្នុងគណៈមេធាវី និងលក្ខណៈសម្បត្តិសម្រាប់ការកំណត់ចំនួនទាំងនេះ។ គណៈកម្មាធិការមានការសោកស្តាយ ចំពោះការខកខានរបស់រដ្ឋភាគីមិនបានឆ្លើយតបទៅនឹងសំណួរនានារបស់គណៈកម្មាធិការ ស្តីពីបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ប្រឆាំងអំពើពុករលួយ ដែលលើកឡើងពីឯករាជ្យភាពរបស់តុលាការ និងផ្តល់ឧទាហរណ៍នៃសំណុំរឿងដែលជនទាំងឡាយណាប្រើប្រាស់ ឬអនុវត្តតាមសម្ពាធមិនត្រឹមត្រូវទៅលើតុលាការ ត្រូវបានស៊ើបអង្កេត ចោទប្រកាន់ និងផ្តន្ទាទោស (មាត្រា ២)។

រដ្ឋភាគីគួរបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីបង្កើត និងធានាឲ្យមានតុលាការមួយដែលមានឯករាជ្យភាពពេញលេញ និងមានវិជ្ជាជីវៈស្របទៅតាមបទដ្ឋានអន្តរជាតិនានា និងធានាថា តុលាការមិនមានការជ្រៀតជ្រែកផ្នែកនយោបាយ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះគួររាប់បញ្ចូលទាំងការអនុម័តជាបន្ទាន់នូវច្បាប់ទាំងអស់ពាក់ព័ន្ធនឹងការកែទម្រង់ ជាពិសេសច្បាប់រៀបចំអង្គការស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការ ច្បាប់ស្តីពីវិសោធនកម្មចំពោះឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងច្បាប់ស្តីពីលក្ខន្តិកៈនៃអង្គចៅក្រម និងព្រះរាជអាជ្ញា។ រដ្ឋភាគីគួរធានាថាបុគ្គលទាំងឡាយណាដែលជាប់ពាក់ព័ន្ធនឹងការដាក់ និងអនុវត្តតាមសម្ពាធមិនត្រឹមត្រូវទៅលើប្រព័ន្ធតុលាការ ត្រូវធ្វើការស៊ើបអង្កេត ចោទប្រកាន់ និងផ្តន្ទាទោស ហើយផ្តល់ឧទាហរណ៍នៃសំណុំរឿងទាំងនេះ។ លើសពីនេះ រដ្ឋភាគីគួរចាត់វិធានការចាំបាច់នានាដើម្បីធានាថា គណៈមេធាវីមានឯករាជ្យភាព តម្លាភាព ហើយបង្កលក្ខណៈទទួលយកមេធាវីឲ្យមានចំនួនគ្រប់គ្រាន់។ លើសពីនេះទៅទៀតគណៈកម្មាធិការស្នើឲ្យរដ្ឋភាគីផ្តល់ព័ត៌មាន ស្តីពីបទប្បញ្ញត្តិនៃច្បាប់ប្រឆាំងអំពើពុករលួយ ដែលលើកឡើងពីឯករាជ្យភាពរបស់តុលាការ។

កិច្ចធានាការពារតាមផ្លូវច្បាប់ជាមូលដ្ឋាន

១៩.គណៈកម្មាធិការមានក្ដីបារម្ភយ៉ាងខ្លាំងចំពោះការខកខានរបស់រដ្ឋភាគីក្នុងការផ្ដល់កិច្ចធានាការពារតាមផ្លូវច្បាប់ជាមូលដ្ឋានដល់ជនជាប់ឃុំទាំងអស់ រាប់ទាំងអនីតិជន និងពិរុទ្ធជនចាប់តាំងពីការឃុំខ្លួនលើកដំបូងរបស់ជនទាំងនេះ។ កិច្ចធានាការពារទាំងនោះរួមមានសិទ្ធិទទួលបានមេធាវីភ្លាមៗ និងការត្រួតពិនិត្យសុខភាពដោយឯករាជ្យតាមការជ្រើសរើសគ្រូពេទ្យដោយខ្លួនឯង មានសិទ្ធិផ្ដល់ដំណឹងដល់សាច់ញាតិ និងត្រូវបានគេប្រាប់ឲ្យបានដឹងអំពីសិទ្ធិទាំងឡាយរបស់ខ្លួនក្នុងពេលឃាត់ខ្លួន/ឃុំខ្លួន ព្រមទាំងការចោទប្រកាន់ប្រឆាំងនឹងពួកគេ ក៏ដូចជាការនាំមកបង្ហាញខ្លួនភ្លាមៗនៅចំពោះមុខចៅក្រមផងដែរ។ គណៈកម្មាធិការមានក្ដីបារម្ភយ៉ាងខ្លាំងថា ក្រមនីតិវិធីព្រហ្មទណ្ឌ មានចែងតែសិទ្ធិរបស់ជនត្រូវឃាត់ខ្លួន/ឃុំខ្លួនក្នុងការទទួលបានការពិគ្រោះយោបល់ជាមួយមេធាវីក្នុងរយៈពេល ២៤ ម៉ោង ក្រោយការចាប់ខ្លួនប៉ុណ្ណោះ ហើយរបាយការណ៍បង្ហាញថា សិទ្ធិសុំឲ្យគ្រូពេទ្យមកពិនិត្យសុខភាពគឺផ្អែកលើឆន្ទានុសិទ្ធិរបស់មន្ត្រីប្រតិបត្តិច្បាប់ ឬមន្ត្រីពន្ធនាគារជាអ្នកសម្រេច។ គណៈកម្មាធិការក៏បង្ហាញពីក្ដីបារម្ភរបស់ខ្លួនផងដែរ ចំពោះចំនួនតិចតួចនៃមេធាវីការពារក្ដី រួមមានមេធាវីការពារក្ដីជំនួយផ្នែកច្បាប់ក្នុងប្រទេស ដែលប្រការនេះធ្វើឲ្យចុងចោទភាគច្រើនមិនអាចទទួលបានការប្រឹក្សាយោបល់ផ្នែកច្បាប់។ គណៈកម្មាធិការក៏មានក្ដីបារម្ភចំពោះរបាយការណ៍ដែលថា ជនដែលត្រូវបានដកហូតសេរីភាព ត្រូវបានឃាត់ខ្លួនទុករយៈពេលយូរក្នុងអង្គភាពឃាត់ខ្លួនរបស់នគរបាល ដោយមិនបានចុះបញ្ជី ហើយថាអង្គភាពឃាត់ខ្លួនរបស់នគរបាល និងពន្ធនាគារភាគច្រើនខកខានមិនបានគោរពតាមបទប្បញ្ញត្តិ ស្ដីពីនីតិវិធីចុះបញ្ជីជនជាប់ឃុំ/ជនត្រូវឃាត់ខ្លួនឡើយ (មាត្រា ២ មាត្រា ១១ និង មាត្រា ១២)។

រដ្ឋភាគីគួរអនុវត្តវិធានការឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពដើម្បីធានាថា ជនជាប់ឃុំទាំងអស់ត្រូវទទួលបានកិច្ចធានាការពារតាមផ្លូវច្បាប់ជាមូលដ្ឋានចាប់ពីពេលឃាត់ខ្លួន/ឃុំខ្លួនលើកដំបូង។ ដើម្បីសម្រេចគោលបំណងនេះ រដ្ឋភាគីគួរធ្វើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌដើម្បីធានាថា ជនជាប់ឃុំមានសិទ្ធិទទួលបានមេធាវីជាបន្ទាន់ ចាប់ពីពេលដែលពួកគេត្រូវបានដកហូតសេរីភាព រហូតដល់ដំណាក់កាលស៊ើបអង្កេត ដំណើរការកាត់ទោសទាំងមូល និងអំឡុងពេលប្ដឹងឧទ្ធរណ៍ ព្រមទាំងមានសិទ្ធិទទួលបានការត្រួតពិនិត្យសុខភាពដោយឯករាជ្យដោយជ្រើសរើសគ្រូពេទ្យដោយខ្លួនឯង ការផ្ដល់ដំណឹងដល់សាច់ញាតិ និងត្រូវបានគេប្រាប់ឲ្យដឹងពីសិទ្ធិទាំងឡាយនៅពេលឃាត់ខ្លួន/ជាប់ឃុំ រាប់ទាំងការចោទប្រកាន់មកលើខ្លួន និងសិទ្ធិបង្ហាញខ្លួនភ្លាមនៅចំពោះមុខចៅក្រមជាដើម។ ដោយចាត់ទុកជាបញ្ហា

បន្ទាន់ រដ្ឋភាគីគួរបង្កើនចំនួនមេធាវីការពារក្តី ដូចជាមេធាវីការពារក្តីជំនួយផ្នែកច្បាប់ក្នុងប្រទេស និងដកចេញនូវរាល់ឧបសគ្គដែលមិនតាមយុត្តិកម្ម ដើម្បីឲ្យបុគ្គលទាំងឡាយអាចចូលជាសមាជិកមេធាវីតាមបំណងរបស់ពួកគេ។ រដ្ឋភាគីគួរធានាឲ្យមានការចុះបញ្ជីឲ្យបានទាន់ពេលវេលាចំពោះជនដែលត្រូវបានដកហូតសេរីភាព ហើយធានាថាត្រូវមានការត្រួតពិនិត្យកំណត់ហេតុឃុំខ្លួន/ឃាត់ខ្លួនតាមពេលកំណត់នៅស្ថានីយនគរបាល និងពន្ធនាគារដើម្បីធ្វើឲ្យប្រាកដថា កំណត់ហេតុទាំងនេះត្រូវរក្សាទុកស្របទៅតាមនីតិវិធីទាំងឡាយ ដែលកំណត់ដោយច្បាប់។

## និទ្ទណ្ឌភាពចំពោះអំពើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន

១៥.គណៈកម្មាធិការនៅតែមានក្តីកង្វល់យ៉ាងខ្លាំង ចំពោះការចោទប្រកាន់ស៊ីសង្វាក់គ្នាយ៉ាងច្រើន និងកំពុងបន្តកើតមានពីបទធ្វើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើជនជាប់ឃុំនៅទីកន្លែងឃុំខ្លួន ជាពិសេសនៅស្ថានីយនគរបាលតែម្តង។ ទាក់ទងនឹងបញ្ហានេះ គណៈកម្មាធិការនៅតែបារម្ភថែមទៀតថា មានការចោទប្រកាន់ជាច្រើនករណីថាមានការប្រព្រឹត្តអំពើហិង្សាផ្លូវភេទប្រឆាំងនឹងស្ត្រីជាប់ឃុំ ដែលបង្កឡើងដោយមន្ត្រីប្រតិបត្តិច្បាប់ និងបុគ្គលិកពន្ធនាគារ។ គណៈកម្មាធិការក៏មានក្តីបារម្ភដែរថា ការចោទប្រកាន់បែបនេះកម្រមានការស៊ើបអង្កេត និងធ្វើការចោទប្រកាន់ណាស់ ហើយនឹងទំនងជាមានបរិយាកាសនិទ្ទណ្ឌភាព ដែលបង្កឲ្យគ្មានការដាក់ពិន័យ ឬកាត់ទោសបទឧក្រិដ្ឋប្រកបដោយអត្ថន័យ ទៅលើបុគ្គលដែលមានអំណាចត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តអំពើទាំងឡាយ ដូចមានចែងនៅក្នុងអនុសញ្ញានេះ។ ថ្វីត្បិតតែមានការកត់សម្គាល់នូវព័ត៌មានពីរដ្ឋភាគីដែលថា ច្បាប់ជាតិនានាជាពិសេសក្រមនីតិវិធីព្រហ្មទណ្ឌ មិនមានបទប្បញ្ញត្តិណាដែលអាចប្រើប្រាស់ជាយុត្តិកម្ម ឬវិធីសម្រាប់ធ្វើជាលេសក្នុងការធ្វើទារុណកម្ម ទោះក្រោមកាលៈទេសៈណាក៏ដោយ ក៏គណៈកម្មាធិការមានក្តីបារម្ភថាក្នុងច្បាប់ជាតិ មិនមានចែងនូវបទប្បញ្ញត្តិស្តីពីការហាមឃាត់ដាច់ខាតមិនឲ្យប្រើប្រាស់កាលៈទេសៈពិសេស មកធ្វើជាលេសក្នុងការធ្វើទារុណកម្មឡើយ (មាត្រា ២ មាត្រា៤ មាត្រា ១២ និងមាត្រា ១៦)។

ដោយចាត់ទុកជាបញ្ហាបន្ទាន់ រដ្ឋភាគីគួរចាត់វិធានការជាបន្ទាន់ និងមានប្រសិទ្ធភាពដើម្បីទប់ស្កាត់អំពើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន រាប់ទាំងអំពើហិង្សាផ្លូវភេទនៅពេលកំពុងឃុំខ្លួន/ឃាត់ខ្លួននៅទូទាំងប្រទេស តាមរយៈការប្រកាសពីគោលនយោបាយដែលនឹងបង្កើតឲ្យមានលទ្ធផលអាចវាស់វែងបាន ក្នុងការលុបបំបាត់អំពើទារុណកម្ម និងប្រព្រឹត្តកម្មមិន

គប្បីមកលើខ្លួនប្រព្រឹត្តឡើងដោយមន្ត្រីរាជការ និងតាមរយៈការឃ្លាំមើល និង/ឬការកត់ត្រានូវដំណើរការសាកសួរចម្លើយរបស់នគរបាល។

រដ្ឋភាគីគួរធានាផងដែរថាការចោទប្រកាន់ពីបទធ្វើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួនទាំងអស់ រួមមានអំពើហិង្សាផ្លូវភេទនៅពេលកំពុងឃុំខ្លួន/ឃាត់ខ្លួន ត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់ ប្រកបដោយប្រសិទ្ធភាព និងមិនលម្អៀង ហើយថាជនល្មើសត្រូវតែបានចោទប្រកាន់ និងផ្តន្ទាទោសឲ្យស្របទៅតាមទម្ងន់នៃអំពើល្មើស តាមលក្ខខណ្ឌតម្រូវនៅក្នុងមាត្រា ៤ នៃអនុសញ្ញា។ រដ្ឋភាគីគួរអនុម័តផែនការកំណត់ទោសសម្រាប់ផ្តន្ទាទោសពីបទធ្វើទារុណកម្ម និង ប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួនប្រព្រឹត្តឡើងដោយមន្ត្រីរដ្ឋាភិបាល ដើម្បីធានាថាមានការផ្តន្ទាទោសធនល្មមចំពោះជន ដែលត្រូវបានរកឃើញថាបានប្រព្រឹត្តអំពើបែបនេះ។

រដ្ឋភាគីគួរធានាថាច្បាប់ជាតិរបស់ខ្លួន មានបញ្ចូលបទប្បញ្ញត្តិដែលហាមឃាត់ដាច់ខាតមិនឲ្យប្រើកាលៈទេសៈពិសេសណាមួយ មកធ្វើជាលេសក្នុងការធ្វើទារុណកម្ម។

## បណ្តឹងតវ៉ា និងការស៊ើបអង្កេតជាបន្ទាន់ប្រកបដោយប្រសិទ្ធភាព និងមិនលម្អៀង

១៦. គណៈកម្មាធិការមានកង្វល់ចំពោះរបាយការណ៍ដែលថា ការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួនពីសំណាក់មន្ត្រីប្រតិបត្តិច្បាប់ និងមន្ត្រីពន្ធនាគារកើតមានឡើងយ៉ាងរាលដាល ហើយការស៊ើបអង្កេត និងការផ្តន្ទាទោសចំពោះករណីបែបនេះមានតិចតួចនៅឡើយ។ គណៈកម្មាធិការក៏មានក្តីបារម្ភផងដែរចំពោះប្រការដែលមិនមានស្ថាប័នស៊ីវិលសម្រាប់ឃ្លាំមើលដោយឯករាជ្យ ដោយមានអំណាចក្នុងការទទួល និងធ្វើការស៊ើបអង្កេតលើបណ្តឹងទាក់ទងនឹងការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួនពីសំណាក់នគរបាល និងមន្ត្រីប្រតិបត្តិច្បាប់ផ្សេងៗទៀត។ គណៈកម្មាធិការមានការសោកស្តាយដែលរដ្ឋភាគី មិនបានផ្តល់ព័ត៌មានលំអិត រាប់ទាំងស្ថិតិស្តីពីចំនួនបណ្តឹងអំពីពើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន ព្រមទាំងលទ្ធផលនៃដំណើរការនីតិវិធីទាំងអស់ទាំងនៅកម្រិតព្រហ្មទណ្ឌ និងដាក់វិន័យរដ្ឋបាល ហើយនិងលទ្ធផលនៃការដោះស្រាយរបស់ពួកគេ។ លើសពីនេះទៅទៀត គណៈកម្មាធិការមានក្តីបារម្ភចំពោះប្រការដែលថាមិនមានយន្តការប្រកបដោយសុវត្ថិភាព ដើម្បីធានាឲ្យមានការការពារជនរងគ្រោះ និងសាក្សី (មាត្រា ១ មាត្រា ២ មាត្រា ៤ មាត្រា ១២ មាត្រា ១៣ និងមាត្រា ១៦)។

រដ្ឋភាគីគួរពង្រឹងវិធានការរបស់ខ្លួនដើម្បីធានាឲ្យមានការស៊ើបអង្កេតជាបន្ទាន់ ប្រកបដោយប្រសិទ្ធភាព និងមិនលម្អៀងលើការចោទប្រកាន់ពីបទធ្វើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួនទាំងអស់លើទណ្ឌិត និងពិរុទ្ធជន រួមទាំងនៅក្នុងស្ថានីយនគរបាល និងដើម្បីយកមន្ត្រីប្រតិបត្តិច្បាប់ និងមន្ត្រីពន្ធនាគារដែលបានប្រព្រឹត្ត និងបញ្ជា ឬបណ្តោតបណ្តោយឲ្យប្រព្រឹត្តអំពើបែបនេះមកផ្តន្ទាទោសតាមផ្លូវច្បាប់។ រដ្ឋភាគីគួរបង្កើតយន្តការប្តឹងតវ៉ាលើការប្រតិបត្តិច្បាប់ដោយឯករាជ្យ និងធានាថាស្ថាប័នស៊ីវិលសម្រាប់ឃ្លាំមើលដោយឯករាជ្យ ធ្វើការស៊ើបអង្កេតលើការប្តឹងតវ៉ាពីបទធ្វើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួនពីសំណាក់មន្ត្រីប្រតិបត្តិច្បាប់។ ទាក់ទងនឹងករណីនៃការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួនតាមការមើលឃើញបឋម ជនសង្ស័យត្រូវតែព្យួរការងារ ឬតែងតាំងការងារជាថ្មីក្នុងអំឡុងពេលធ្វើការស៊ើបអង្កេត ដើម្បីចៀសវាងប្រការគ្រោះថ្នាក់ណាមួយ ដែលជនសង្ស័យនោះអាចបង្កឲ្យមានការរាំងស្ទះដល់ការស៊ើបអង្កេត ឬបន្តធ្វើសកម្មភាពដែលមិនអនុញ្ញាតដូចដែលបានរាយការណ៍ ដែលរំលោភបំពានទៅលើអនុសញ្ញា។

លើសពីនេះទៅទៀត រដ្ឋភាគីគួរបង្កើតកម្មវិធីការពារជនរងគ្រោះ និងសាក្សីដើម្បីជួយធានាឲ្យមានការរក្សាការសម្ងាត់ និងដើម្បីការពារអ្នកដែលចេញមុខមករាយការណ៍ ឬប្តឹងតវ៉ាទាក់ទងនឹងអំពើទារុណកម្ម ក៏ដូចជាធានាឲ្យមានការបែងចែកមូលនិធិគ្រប់គ្រាន់សម្រាប់ការប្រព្រឹត្តទៅរបស់ខ្លួនឲ្យមានប្រសិទ្ធភាព។

## ការឃុំខ្លួនបណ្តោះអាសន្នដែលអូសបន្លាយពេលវេលាយូរ

១៧.គណៈកម្មាធិការបានកត់សម្គាល់ដោយក្តីបារម្ភថា ប្រព័ន្ធយុត្តិធម៌ផ្នែកព្រហ្មទណ្ឌរបស់រដ្ឋភាគី នៅតែបន្តពឹងផ្អែកលើការឃុំខ្លួនជនជាប់ចោទដែលរង់ចាំការជំនុំជម្រះជាជម្រើសខុសឆ្គង ហើយគណៈកម្មាធិការនៅតែមានក្តីបារម្ភចំពោះការពន្យារពេលអូសបន្លាយដែលមិនចាំបាច់ សំរាប់ការឃុំខ្លួនបណ្តោះអាសន្នដែលក្នុងអំឡុងពេលឃុំនេះ អាចនឹងទទួលរងការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួនផ្សេងៗ (មាត្រា ២ និងមាត្រា ១១)។

រដ្ឋភាគីគួរអនុម័តវិធានការដែលមានប្រសិទ្ធភាពដើម្បីធានាថា គោលនយោបាយឃុំខ្លួនបណ្តោះអាសន្នស្របទៅតាមបទដ្ឋានអន្តរជាតិ ហើយគោលនយោបាយនោះយកមកប្រើប្រាស់សម្រាប់តែជាវិធានការពិសេសមួយក្នុងរយៈពេលកំណត់តែប៉ុណ្ណោះ អនុលោមតាមលក្ខខណ្ឌតម្រូវក្រោមរដ្ឋធម្មនុញ្ញ និងក្រមនីតិវិធីព្រហ្មទណ្ឌ។ ដើម្បីសម្រេចគោលបំណងនេះ រដ្ឋភាគីគួរពិចារណាឡើងវិញលើការប្រើប្រាស់វិធីឃុំខ្លួនជនជាប់ចោទដែលរង់ចាំការកាត់ទោសជាជម្រើសខុសឆ្គង និងពិចារណាលើការអនុវត្តវិធានការផ្សេងៗជំនួសឲ្យការឃុំខ្លួនបណ្តោះអាសន្នបែបនេះ ដូចជាការដោះលែងឲ្យនៅក្រៅឃុំស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានមុនពេលសវនាការ។ រដ្ឋភាគីគួរអនុវត្ត និងបង្កើតបទប្បញ្ញត្តិច្បាប់បន្ថែមទៀតឲ្យបានទូលំទូលាយផងដែរ ដែលអនុញ្ញាតឲ្យមានវិធានការមិនឃុំខ្លួន។

## ការឃ្លាំមើល និងអធិការកិច្ចនៅតាមទីកន្លែងឃុំខ្លួន

១៨.គណៈកម្មាធិការកត់សម្គាល់ដោយចាប់អារម្មណ៍ នូវព័ត៌មានដែលទទួលបានពីរដ្ឋភាគីដែលថា ស្ថាប័នទទួលខុសត្រូវមួយចំនួនមានសិទ្ធិ និងអំណាចធ្វើអធិការកិច្ចជាប្រចាំនៅតាមពន្ធនាគារ។ គណៈកម្មាធិការក៏កត់សម្គាល់ផងដែរនូវព័ត៌មានដែលផ្តល់ដោយរដ្ឋភាគីថា អង្គការមិនមែនរដ្ឋាភិបាល (NGOs) "ដែលជាប់ពាក់ព័ន្ធ" ទទួលបានការអនុញ្ញាតឲ្យធ្វើទស្សនកិច្ចពិនិត្យមើលពន្ធនាគារ។ ទោះជាយ៉ាងនេះក្តី គណៈកម្មាធិការនៅតែមានការព្រួយបារម្ភ ចំពោះការខ្វះខាតព័ត៌មានទាក់ទងនឹងការឃ្លាំមើល និងការធ្វើអធិការកិច្ចដែលមានប្រសិទ្ធភាពនៅតាមទីកន្លែងឃុំខ្លួនទាំងអស់ រួមមានស្ថានីយនគរបាល ពន្ធនាគារ មណ្ឌលសង្គមកិច្ច មណ្ឌលបន្សាបសារធាតុញៀននិងទីកន្លែងដទៃទៀត ដែលមនុស្សមួយចំនួននៅកន្លែងទាំងនេះត្រូវបានដកហូតសេរីភាព។ ទាក់ទងនឹងបញ្ហានេះ គណៈកម្មាធិការមានក្តីបារម្ភយ៉ាងខ្លាំងចំពោះការខកខានរបស់រដ្ឋភាគី ក្នុងការផ្តល់ព័ត៌មានអំពីថាតើមានដំណើរទស្សនកិច្ចបែបនេះទៅកាន់ទីកន្លែងឃុំខ្លួនដោយមិនប្រកាសឲ្យដឹងជាមុន ឬក៏ស្ថិតក្រោមការត្រួតពិនិត្យ ព្រមទាំងព័ត៌មានស្តីពីការពិនិត្យតាមដានលើលទ្ធផលនៃដំណើរទស្សនកិច្ចទាំងនោះដែរ ឬយ៉ាងណានោះទេ (មាត្រា ២ មាត្រា ១១ និងមាត្រា ១៦)។

គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីបង្កើតប្រព័ន្ធថ្នាក់ជាតិមួយ ដើម្បីឃ្លាំពិនិត្យមើល និងធ្វើអធិការកិច្ចដែលមានប្រសិទ្ធភាពនៅគ្រប់ទីកន្លែងឃុំខ្លួន រួមមានស្ថានីយនគរបាល ពន្ធនាគារ មណ្ឌលសង្គមកិច្ច មណ្ឌលបន្សាបសារធាតុញៀននិងទីកន្លែងដទៃទៀត ដែលមនុស្សនៅកន្លែង

ទាំងនេះត្រូវបានដកហូតសេរីភាព និងពិនិត្យតាមដានដើម្បីធានាឲ្យមានការឃ្លាំពិនិត្យមើលប្រកបដោយប្រសិទ្ធភាព។ ប្រព័ន្ធនេះត្រូវដាក់បញ្ចូលដំណើរទស្សនកិច្ចត្រួតពិនិត្យជាប្រចាំ និងដោយមិនប្រកាសឲ្យដឹងជាមុនពីសំណាក់អ្នកឃ្លាំពិនិត្យមើលឯករាជ្យថ្នាក់ជាតិ និងអន្តរជាតិ រួមមានអង្គការមិនមែនរដ្ឋាភិបាល (NGOs) "ដែលជាប់ពាក់ព័ន្ធ" ដើម្បីទប់ស្កាត់ការធ្វើទារុណកម្ម និងប្រព្រឹត្តកម្ម ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។

## លក្ខខណ្ឌនៃការឃុំខ្លួន

១៩. គណៈកម្មាធិការកត់សំគាល់លើវិធានការនានា ដែលបានអនុម័តដោយរដ្ឋភាគី ដើម្បីលើកកម្ពស់លក្ខខណ្ឌនៃការឃុំខ្លួន រួមមានតាមរយៈកម្មវិធីគាំទ្រកំណែទម្រង់ពន្ធនាគារ (PRSP) ការចេញអនុក្រឹត្យស្តីពីការកំណត់របបអាហារ និងសម្ភារៈប្រើប្រាស់សម្រាប់អ្នកទោស សេចក្តីព្រាងបទដ្ឋានអប្បបរមាសម្រាប់ការសាងសង់ពន្ធនាគារ ដោយសហការជាមួយដៃគូអន្តរជាតិ និងការសាងសង់ពន្ធនាគារថ្មីៗ។ ទោះជាយ៉ាងនេះក្តី គណៈកម្មាធិការក៏មានក្តីបារម្ភចំពោះភាពចង្អៀតណែននៅទីកន្លែងដែលមនុស្សនៅកន្លែងទាំងនោះ ត្រូវបានដកហូតសេរីភាពដែលជាសញ្ញាគំរាមកំហែងដល់សុវត្ថិភាព បូរណភាពផ្លូវកាយ និងផ្លូវចិត្ត និងសុខភាពរបស់ជនជាប់ឃុំ។ គណៈកម្មាធិការក៏មានក្តីបារម្ភពីរបាយការណ៍ ទាក់ទងនឹងភាពគ្មានអនាម័យ ម្ហូបអាហារមិនគ្រប់គ្រាន់ និងការថែទាំសុខភាពមិនបានត្រឹមត្រូវ។ គណៈកម្មាធិការក៏កត់សម្គាល់ដោយក្តីបារម្ភចំពោះអ្នកទោសក្នុងពន្ធនាគារ មានចំនួនកើនឡើងជាលំដាប់ និងការដាក់ទោសទណ្ឌដោយគ្មានទំរង់មិនឃុំខ្លួន។ លើសពីនេះទៅទៀត គណៈកម្មាធិការកត់សម្គាល់ដោយក្តីបារម្ភយ៉ាងខ្លាំង ចំពោះរបាយការណ៍លើករណីមរណភាពក្នុងអំឡុងពេលឃុំខ្លួន/ឃាត់ខ្លួន ព្រមទាំងសោកស្តាយចំពោះការខកខានរបស់រដ្ឋភាគីក្នុងការផ្តល់ព័ត៌មានស្តីពីបញ្ហានេះ។ គណៈកម្មាធិការក៏មានក្តីបារម្ភយ៉ាងខ្លាំងចំពោះការចោទប្រកាន់ថា រដ្ឋភាគីមិនបានផ្តល់ព័ត៌មានស្តីពី "គណៈកម្មាធិការស្វ័យគ្រប់គ្រងពន្ធនាគារ" ដែលជួនកាលជាអ្នកទទួលខុសត្រូវចំពោះការរំលោភបំពានយ៉ាងហិង្សា និងប្រព្រឹត្តកម្មមិនគប្បីមកលើអ្នកទោសដ៏ទៃទៀតក្នុងរយៈពេលកំពុងទទួលរងវិធានការវិន័យ ហើយជាញឹកញាប់អគ្គនាយកដ្ឋានពន្ធនាគារ (GDP) មិនបានអើពើ ឬក៏បណ្តែតបណ្តោយឲ្យមានការប្រព្រឹត្តអំពើបែបនេះ។ គណៈកម្មាធិការក៏មានក្តីបារម្ភដែរថាជនជាប់ឃុំជាស្ត្រី និងបុរសត្រូវបានដាក់ឲ្យនៅជាមួយគ្នា ហើយបុគ្គលិកពន្ធនាគារជាបុរស នៅតែបន្តចាំយាមការពារជនជាប់ឃុំជា

ស្ត្រី ដោយសារតែខ្វះបុគ្គលិកពន្ធនាគារជាស្ត្រី (មាត្រា ១ មាត្រា ២ មាត្រា ៤ មាត្រា ១១ និងមាត្រា ១៦)។

រដ្ឋភាគីគួរពង្រីកកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីកាត់បន្ថយភាពចង្អៀតណែនហួសហេតុ ឲ្យមានប្រសិទ្ធភាពនៅទីកន្លែងទាំងឡាយ ដែលមនុស្សត្រូវបានដកហូតសេរីភាព រួមមានស្ថានីយនគរបាលនិងពន្ធនាគារ ហើយដើម្បីកែលំអលក្ខខណ្ឌឃុំខ្លួននៅតាមទីកន្លែងទាំងនេះ មានដូចជាអនាម័យ និងការផ្គត់ផ្គង់ម្ហូបអាហារជាដើម។ ដើម្បីសម្រេចបានគោលបំណងនេះ គណៈកម្មាធិការសូមលើកជាអនុសាសន៍ថា រដ្ឋភាគីត្រូវអនុវត្តវិធានការផ្សេងៗជំនួសឲ្យការដាក់ពន្ធនាគារ និងធានាឲ្យមានការបែងចែកថវិកាគ្រប់គ្រាន់ ដើម្បីអភិវឌ្ឍនិងជួសជុលហេដ្ឋារចនាសម្ព័ន្ធពន្ធនាគារ និងទីកន្លែងឃុំខ្លួនផ្សេងៗទៀត។ លើសពីនេះ រដ្ឋភាគីគួរបង្កើត និងកំណត់មុខងារ និងតួនាទីរបស់ "គណៈកម្មាធិការស្វ័យគ្រប់គ្រងពន្ធនាគារ" ឲ្យបានច្បាស់លាស់ និងធានាថាមានការស៊ើបអង្កេតលើករណីរំលោភបំពាន និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួនពីសំណាក់អង្គភាពនេះ ហើយជនល្មើសត្រូវតែបានដាក់ទណ្ឌកម្ម។ បន្ថែមពីនេះ មន្ត្រីអគ្គនាយកដ្ឋានពន្ធនាគារដែលមិនអើពើ ឬបណ្ដែតបណ្ដោយឲ្យមានការប្រព្រឹត្តអំពើទាំងនេះ ត្រូវទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ដោយជនសង្ស័យត្រូវផ្អាកពីការងារ ឬចាត់តាំងការងារសាជាថ្មីក្នុងអំឡុងពេលដំណើរការស៊ើបអង្កេត។ គណៈកម្មាធិការក៏ស្នើសុំផងដែរឲ្យផ្ដល់ព័ត៌មានថ្មីៗ ស្ដីពីកាលៈទេសៈទាំងឡាយជុំវិញមរណភាពរបស់ជនជាប់ឃុំឈ្មោះ គង់ ឡា, ហេង ទូច និងម៉ៅ សុខ ព្រមទាំងព័ត៌មានស្ដីពីការស៊ើបអង្កេត ការចោទប្រកាន់ និងការផ្ដន្ទាទោសដែលកើតចេញពីករណីទាំងនេះ។

រដ្ឋភាគីគួរពិនិត្យឡើងវិញផងដែរនូវគោលនយោបាយ និងនីតិវិធីទាំងឡាយស្ដីពីការឃុំខ្លួន/ឃាត់ខ្លួន និងការប្រព្រឹត្តមកលើជនជាប់ឃុំ រួមមាននៅស្ថានីយនគរបាល គួរធានាថាជនជាប់ឃុំជាស្ត្រី និងបុរស ត្រូវដាក់ឲ្យនៅដាច់ដោយឡែកពីគ្នា ហើយជនជាប់ឃុំជាស្ត្រីត្រូវតែបានយាមការពារដោយមន្ត្រីដែលមានភេទដូចគ្នា ត្រូវឃ្លាំពិនិត្យមើល និងចងក្រងឯកសារស្ដីពីឧប្បត្តិហេតុនៃអំពើហិង្សាផ្លូវភេទក្នុងពេលឃុំខ្លួន/ឃាត់ខ្លួន និងផ្ដល់ទិន្នន័យស្ដីពីបញ្ហាទាំងនេះ ដោយបែងចែកទៅតាមសូចនាករដែលពាក់ព័ន្ធជូនគណៈកម្មាធិការ។ គណៈកម្មាធិការសូមលើកអនុសាសន៍ផងដែរថា រដ្ឋភាគីត្រូវធ្វើការពិចារណាលើការចងក្រងព័ត៌មានពិស្ដារ ស្ដីពីស្ថិតិពន្ធនាគារដែលអាចជឿជាក់បាន និងមានភាពត្រឹមត្រូវ រួមទាំងព័ត៌មានលំអិតស្ដីពីរយៈពេលដាក់ទោស ប្រភេទនៃបទល្មើស និងអាយុរបស់ជនល្មើស ដើម្បីជួយផ្ដល់ព័ត៌មានពីសេចក្ដីសម្រេចលើគោលនយោបាយយុត្តិធម៌ព្រហ្មទណ្ឌ។

មណ្ឌលសង្គមកិច្ច

២០.គណៈកម្មាធិការកត់សម្គាល់ពីព័ត៌មាន និងការបំភ្លឺរបស់គណៈប្រតិភូទាក់ទងនឹងមណ្ឌលសង្គមកិច្ច រួមទាំងការបំភ្លឺដែលថារដ្ឋភាគីបានព្រមព្រៀងជាមួយអង្គការយូនីសេហ្វ និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា ដើម្បីធ្វើការវាយតម្លៃលើគោលនយោបាយ នីតិវិធី និងការអនុវត្តដែលមានស្រាប់ក្នុងការបញ្ជូន ការដាក់ឲ្យស្នាក់នៅ ការគ្រប់គ្រង ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មទៅក្នុងសង្គមជាតិវិញនូវកុមារ ស្ត្រី និងជនងាយរងគ្រោះ ដែលរស់នៅតាមមណ្ឌលសង្គមកិច្ច និងមជ្ឈមណ្ឌលយុវនីតិសម្បទានៅទូទាំងប្រទេស។ ទោះបីយ៉ាងណាក៏ដោយ គណៈកម្មាធិការមានក្តីបារម្ភខ្លាំងចំពោះរបាយការណ៍ជាបន្តបន្ទាប់ ស្តីពីការចុះចាប់ប្រជាពលរដ្ឋនៅតាមដងផ្លូវសាធារណៈពីសំណាក់មន្ត្រីប្រតិបត្តិច្បាប់ ហើយបន្ទាប់មកធ្វើការឃុំខ្លួនប្រជាពលរដ្ឋទាំងនេះក្នុងមណ្ឌលសង្គមកិច្ចប្រឆាំងនឹងឆន្ទៈរបស់ពួកគេ ប្រជាពលរដ្ឋទាំងនេះមានដូចជាស្ត្រីរកស៊ីផ្លូវភេទ ជនរងគ្រោះដោយការជួញដូរ អ្នកប្រើប្រាស់គ្រឿងញៀន ជនអនាថា អ្នកសុំទាន កុមារអនាថា និងជនវិកលចរិត ដោយគ្មានមូលដ្ឋានច្បាប់ និងដីកាពីតុលាការឡើយ។ លើសពីនេះ គណៈកម្មាធិការមានក្តីបារម្ភខ្លាំង និងកត់សម្គាល់នូវការចោទប្រកាន់ទាំងឡាយ ដែលមានបែបផែនស៊ីសង្វាក់គ្នាស្តីពីការរំលោភបំពាន និងការឃុំឃាំងតាមទំនើងចិត្តក្នុងមណ្ឌលសង្គមកិច្ចព្រៃស្ពឺក្នុងចន្លោះចុងឆ្នាំ ២០០៦ និង ២០០៨ រួមមានការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ ការវាយដំ សេចក្តីរាយការណ៍ពីឧប្បត្តិហេតុអត្តឃាត និងសេចក្តីរាយការណ៍ពីការសម្លាប់អ្នកជាប់ឃុំដោយមន្ត្រីឆ្មាំនៅមណ្ឌលសង្គមកិច្ច។ គណៈកម្មាធិការមានក្តីបារម្ភចំពោះការមិនទទួលបានព័ត៌មានគ្រប់គ្រាន់ ទាក់ទងនឹងការផ្តួចផ្តើមគំនិតរបស់រដ្ឋភាគី ក្នុងការស៊ើបអង្កេតឲ្យបានហ្មត់ចត់ទៅលើការចោទប្រកាន់ទាំងនេះ (មាត្រា២, មាត្រា ១១ និងមាត្រា ១៦)។

គណៈកម្មាធិការជំរុញរដ្ឋភាគីឲ្យបញ្ឈប់ការឃុំឃាំងមនុស្សតាមទំនើងចិត្ត និងខុសច្បាប់តាមគ្រប់រូបភាពទាំងស្រុង ជាពិសេសក្នុងមណ្ឌលសង្គមកិច្ច រួមទាំងមណ្ឌលព្រៃស្ពឺ។ រដ្ឋភាគីគួរធានាថាស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធទាំងអស់ គោរពសិទ្ធិដោយមិនត្រូវបានឃុំឃាំងតាមអំពើចិត្តផ្អែកលើឋានៈក្នុងសង្គមតាមទស្សនៈរដ្ឋាភិបាល និងដោយគ្មានមូលដ្ឋានច្បាប់ និងដីកាពីតុលាការឡើយ។ រដ្ឋភាគីក៏គួរធានាផងដែរថា មន្ត្រី/ឆ្មាំគុក និងអ្នកផ្សេងទៀតពាក់ព័ន្ធក្នុងការ

រំលោភបំពាន និងការឃុំឃាំងតាមអំពើចិត្ត នឹងត្រូវធ្វើការអង្កេត និងចោទប្រកាន់ឲ្យបានឆាប់រហ័សចំពោះទង្វើរបស់ខ្លួន និងធានាថាជនរងគ្រោះទទួលបានសំណងត្រឹមត្រូវតាមផ្លូវច្បាប់។

ដោយចាត់ទុកជាបញ្ហាបន្ទាន់ រដ្ឋភាគីគួរធ្វើការស៊ើបអង្កេតដោយឯករាជ្យ ចំពោះការចោទប្រកាន់ពីការរំលោភបំពានដ៏ធ្ងន់ធ្ងរលើសិទ្ធិមនុស្ស រួមទាំងការធ្វើទារុណកម្មក្នុងមណ្ឌលព្រៃស្ពឺ ក្នុងចន្លោះចុងឆ្នាំ២០០៦ និង២០០៨។ លើសពីនេះ គណៈកម្មាធិការលើកទឹកចិត្តដល់រដ្ឋភាគីឲ្យធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធដទៃទៀត ដើម្បីរិះរកជម្រើសផ្សេងៗដែលមាននិរន្តរភាព និងមានមនុស្សធម៌សម្រាប់ក្រុមមនុស្សរងគ្រោះ និងក្រុមងាយរងគ្រោះ រួមទាំងអ្នករស់នៅ និងធ្វើការតាមដងផ្លូវសាធារណៈ និងដើម្បីផ្តល់ជំនួយតាមតម្រូវការរបស់ពួកគេ។

អំពើហិង្សាផ្លូវភេទ រួមមានការរំលោភសេពសន្ថវៈ

២១. យោងតាមផែនការយុទ្ធសាស្ត្រនារីរតនៈ ៥ ឆ្នាំ ដំណាក់ការទី ៣ ឆ្នាំ២០០៩-២០១៣ របស់រដ្ឋភាគី គណៈកម្មាធិការមានក្តីបារម្ភយ៉ាងខ្លាំង ចំពោះអំពើហិង្សាលើស្ត្រីក្នុងប្រទេសកម្ពុជា ដែលនៅតែបន្តកើតមានយ៉ាងរាលដាល និងកំណើនអំពើហិង្សាលើស្ត្រីក្នុងរូបភាពជាអំពើហិង្សាលើយេនឌ័រ ជាពិសេសការរំលោភសេពសន្ថវៈ។ តាមរយៈរបាយការណ៍ពីប្រភពមិនមែនរដ្ឋាភិបាល គណៈកម្មាធិការក៏មានក្តីបារម្ភយ៉ាងខ្លាំងផងដែរ ចំពោះកំណើនរបាយការណ៍ស្តីពីករណីរំលោភសេពសន្ថវៈ រួមទាំងការរំលោភសេពសន្ថវៈលើកុមារី និងការរំលោភសេពសន្ថវៈដោយជនល្មើសច្រើននាក់ ដែលជាអំពើហិង្សា និងការរំលោភបំពានផ្លូវភេទ ជាពិសេសទៅលើប្រជាជនក្រីក្រ ហើយជនរងគ្រោះជាស្ត្រី និងកុមារដែលទទួលរងអំពើហិង្សានេះ មានលទ្ធភាពតិចតួចក្នុងការទទួលបានយុត្តិធម៌ និងគ្មានសេវាវេជ្ជសាស្ត្រ និងការគាំទ្រផ្លូវចិត្តសំរាប់ជនរងគ្រោះឡើយ។ (មាត្រា ១ មាត្រា ២ មាត្រា ៤ មាត្រា ១១ មាត្រា ១៣ និងមត្រា ១៦)។

រដ្ឋភាគីគួរចាត់វិធានការដែលមានប្រសិទ្ធភាព ក្នុងការការពារនិងប្រយុទ្ធប្រឆាំងនឹងអំពើហិង្សា និងការរំលោភបំពានផ្លូវភេទទៅលើស្ត្រីនិងកុមារ រួមទាំងការរំលោភសេពសន្ថវៈ។ ដើម្បីសម្រេចគោលបំណងនេះ រដ្ឋភាគីគួរបង្កើត និងលើកកម្ពស់យន្តការប្រកបដោយប្រសិទ្ធភាពមួយ សំរាប់ទទួលពាក្យបណ្តឹងទាក់ទងនឹងអំពើហិង្សាផ្លូវភេទ និងធ្វើការស៊ើបអង្កេតលើពាក្យបណ្តឹងទាំងនោះ ដោយផ្តល់ការការពារខាងវេជ្ជសាស្ត្រ និងផ្លូវចិត្តដល់ជនរងគ្រោះ ក៏ដូចជាលទ្ធភាពទទួលបានដំណោះស្រាយ រួមមានសំណង និងការស្តារនីតិសម្បទាបានសមស្រប។ គណៈកម្មាធិការស្នើសុំឲ្យរដ្ឋភាគី ផ្តល់ស្ថិតិនៃចំនួនបណ្តឹងទាក់ទងនឹងការរំលោភសេពសន្ថវៈ

ក៏ដូចជាព័ត៌មានស្ដីពីការស៊ើបអង្កេត ការចោទប្រកាន់ និងការផ្ដន្ទាទោសនៅក្នុងសំណុំរឿងទាំងនេះ។

ការជួញដូរមនុស្ស

២២.គណៈកម្មាធិការសូមស្វាគមន៍រាល់ព័ត៌មានទទួលបានពីគណៈប្រតិភូ ស្ដីពីការចាត់វិធានការក្នុងការធ្វើមាតុភូមិនិវត្តន៍របស់ជនរងគ្រោះ និងការពារអ្នកទាំងនោះដែលរងគ្រោះដោយសារការជួញដូរ ការអនុម័តច្បាប់ប្រឆាំងនឹងការជួញដូរមនុស្សក្នុងឆ្នាំ ២០០៨ និងផែនការជាតិទី ២ ស្ដីពីការជួញដូរមនុស្ស និងការជួញដូរផ្លូវភេទឆ្នាំ ២០០៦-២០១០ សកម្មភាពរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការការពារអនីតិជននៃក្រសួងមហាផ្ទៃ ក៏ដូចជាការចាត់វិធានការតាមផ្លូវច្បាប់ រដ្ឋបាល និងវិធានការនគរបាលផ្សេងៗទៀត ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរ។ ទោះបីយ៉ាងណាក៏ដោយ គណៈកម្មាធិការកត់សម្គាល់ដោយមានការព្រួយបារម្ភយ៉ាងខ្លាំង នូវរបាយការណ៍ដែលថាចំនួនស្ត្រី និងកុមារជាច្រើននៅតែទទួលរងការជួញដូរនៅទូទាំងប្រទេស ចេញពីប្រទេស និងនៅក្នុងប្រទេសក្នុងគោលបំណងធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើការងារដោយបង្ខំ។ គណៈកម្មាធិការក៏មានក្ដីបារម្ភផងដែរ ចំពោះការមិនទទួលបានស្ថិតិពីរដ្ឋភាគី រួមទាំងចំនួនពាក្យបណ្ដឹង ការស៊ើបអង្កេត ការចោទប្រកាន់ និងការផ្ដន្ទាទោសចំពោះជនល្មើសដែលជួញដូរមនុស្ស និងការខ្វះខាតព័ត៌មានស្ដីពីវិធានការជាក់ស្ដែង ដែលត្រូវអនុវត្តដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងទៅនឹងបាតុភូតទាំងនេះ រួមទាំងវិធានការវេជ្ជសាស្ត្រ សង្គម និងស្តារ-នីតិសម្បទា។ (មាត្រា ១ មាត្រា ២ មាត្រា ៤, មាត្រា ១២ និងមាត្រា ១៦)។

រដ្ឋភាគីគួរបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការការពារ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជាពិសេសការជួញដូរស្ត្រី និងកុមាររួមទាំងអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស ផ្ដល់ការការពារដល់ជនរងគ្រោះ និងធានាថាជនរងគ្រោះមានលទ្ធភាពទទួលបានសេវាវេជ្ជសាស្ត្រ សង្គម ស្តារនីតិសម្បទា និងសេវាច្បាប់ រួមមានសេវាប្រឹក្សាយោបល់ប្រកបដោយភាពសមស្រប។ រដ្ឋភាគីក៏គួរបង្កើតលក្ខខណ្ឌឲ្យបានសមរម្យផងដែរសម្រាប់ជនរងគ្រោះ ដើម្បីអាចឲ្យពួកគេប្រើប្រាស់សិទ្ធិក្នុងការដាក់ពាក្យបណ្ដឹង ធ្វើការស៊ើបអង្កេតឲ្យបានទាន់ពេលវេលា មិនលំអៀង និងមានប្រសិទ្ធភាពលើការចោទប្រកាន់ទាំងអស់ពីបទជួញដូរមនុស្ស និងធានាថាអ្នកដែលរកឃើញថាមានពិរុទ្ធពីបទឧក្រិដ្ឋទាំងនេះ នឹងត្រូវផ្ដន្ទាទោសស្របតាមចរិតលក្ខណៈនៃបទឧក្រិដ្ឋដែលពួកគេបានប្រព្រឹត្ត។

## កុមារជាប់ឃុំ

២៣.គណៈកម្មាធិការសូមស្វាគមន៍រាល់កិច្ចប្រឹងប្រែងរបស់រដ្ឋភាគី ក្នុងការធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌សម្រាប់អនីតិជន រួមទាំងសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌របស់អនីតិជន និងការបង្កើតក្រុមការងារអន្តរក្រសួងស្តីពីយុត្តិធម៌កុមារក្នុងឆ្នាំ២០០៦។ ទោះបីយ៉ាងណាក៏ដោយ គណៈកម្មាធិការមានក្តីបារម្ភចំពោះរបាយការណ៍ ពីការកើនឡើងខ្ពស់នៃចំនួនអនីតិជនជាប់ឃុំ និងការមិនមានជម្រើសផ្សេងទៀតជំនួសឲ្យការឃុំខ្លួន។ គណៈកម្មាធិការក៏បង្ហាញពីក្តីបារម្ភផងដែរ ចំពោះការឃុំឃាំងកុមារជាមួយមនុស្សពេញវ័យនៅតាមទីកន្លែងឃុំខ្លួននានា។ (មាត្រា ២ មាត្រា ១១ និងមាត្រា ១៦)។

ដោយចាត់ទុកជាបញ្ហាបន្ទាន់ រដ្ឋភាគីគួរបង្កើតប្រព័ន្ធយុត្តិធម៌សម្រាប់អនីតិជនដាច់ដោយឡែក សមស្របតាមតម្រូវការ ស្ថានភាព និងលក្ខខណ្ឌតម្រូវពិសេសរបស់អនីតិជន។ ដើម្បីសម្រេចគោលបំណងនេះ រដ្ឋភាគីគួរអនុម័តសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌របស់អនីតិជនឲ្យបានឆាប់រហ័ស និងធានាថាសេចក្តីព្រាងច្បាប់នេះ មានភាពសមស្របតាមបទដ្ឋានអន្តរជាតិ និងគួរបង្កើតគោលការណ៍ណែនាំ និងសារាចរណែនាំដែលស៊ីសង្វាក់គ្នាស្តីពីទស្សនៈប្រព័ន្ធយុត្តិធម៌កុមារមេត្រី សម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងនគរបាលយុត្តិធម៌។ រដ្ឋភាគីគួរបន្តចាត់វិធានការចាំបាច់ទាំងអស់ដើម្បីបង្កើត និងអនុវត្តប្រព័ន្ធដ៏ទូលំទូលាយមួយនៃវិធានការជំនួសការដាក់ពន្ធនាគារ ដើម្បីធានាថាការដកហូតសិទ្ធិសេរីភាពរបស់អនីតិជន អាចអនុវត្តសម្រាប់តែជាជម្រើសចុងក្រោយក្នុងរយៈពេលដ៏ខ្លីបំផុតតាមដែលអាចធ្វើទៅបាន និងក្នុងលក្ខខណ្ឌសមស្រប។ លើសពីនេះរដ្ឋភាគីគួរចាត់វិធានការចាំបាច់ ដើម្បីធានាថាអនីតិជនដែលមានអាយុក្រោម ១៨ ឆ្នាំ មិនត្រូវឃុំខ្លួនជាមួយមនុស្សពេញវ័យឡើយ។

## ជនភៀសខ្លួន និងគោលការណ៍មិនបញ្ជូនត្រឡប់

២៤.ទោះបីជាគណៈកម្មាធិការសម្តែងការស្វាគមន៍ដល់រដ្ឋភាគី ដែលបានគោរពតាមសន្ធិសញ្ញាឆ្នាំ១៩៥១ ទាក់ទងនឹងស្ថានភាពជនភៀសខ្លួនក៏ដោយ ក៏គណៈកម្មាធិការមានក្តីបារម្ភចំពោះការមិនទទួលបានព័ត៌មាន ស្តីពីច្បាប់ជាតិដែលធានាដល់សិទ្ធិរបស់ជនភៀសខ្លួន និងអ្នកសុំសិទ្ធិជ្រកកោន រួមទាំងកុមារកំព្រាដែលត្រូវការ

ការពារពីអន្តរជាតិ។ គណៈកម្មាធិការក៏មានក្ដីបារម្ភផងដែរថា មិនមានបទប្បញ្ញត្តិច្បាប់ច្បាស់លាស់ ដែលត្រូវហាមឃាត់ចំពោះការបណ្ដេញចេញ ការបញ្ជូនត្រឡប់ ឬការធ្វើបត្យាប័នមនុស្សទៅកាន់រដ្ឋផ្សេងៗទៀត នៅពេលមានមូលដ្ឋានគ្រប់គ្រាន់អាចជឿជាក់បានថា ជននោះនឹងស្ថិតក្នុងស្ថានភាពប្រឈមនឹងការធ្វើទារុណកម្ម។ គណៈកម្មាធិការកាន់តែមានក្ដីព្រួយបារម្ភចំពោះមនុស្សកាន់តែច្រើន ដែលមិនអាចទទួលបានការការពារពេញលេញ ដូចបានចែងក្នុងមាត្រា ៣ នៃអនុសញ្ញានេះ ក្នុងករណីមានការបណ្ដេញចេញ ការបញ្ជូនត្រឡប់ ឬការនិរទេសទៅកាន់ប្រទេសដើមកំណើតវិញ។ ករណីបែបនេះ រាប់ទាំងអ្នកសុំសិទ្ធិជ្រកកោនជាម៉ុងតាញ៉ាចំនួន ៦៧៤ នាក់ដែលពួកគេលែងជាប្រជាជនរបស់រដ្ឋភាគី និងការចាប់បញ្ជូនអ្នកសុំសិទ្ធិជ្រកកោនជនជាតិអ៊ុយហ្គួដោយបង្ខំចំនួន ២០ នាក់ទៅកាន់ប្រទេសចិនវិញកាលពីខែធ្នូ ឆ្នាំ២០០៩ ព្រមទាំងការខ្វះខាតព័ត៌មានស្ដីពីការចាត់វិធានការដោយរដ្ឋភាគីក្នុងការតាមដានស្ថានភាពរបស់អ្នកទាំងនោះ (មាត្រា ៣ មត្រា ១២ និងមាត្រា ១៣)។

រដ្ឋភាគីគួរបង្កើត និងអនុម័តច្បាប់ជាតិស្ដីពីការធានាសិទ្ធិរបស់ជនភៀសខ្លួន និងអ្នកសុំសិទ្ធិជ្រកកោន រួមទាំងកុមារកំព្រាដែលត្រូវការការពារពីអន្តរជាតិផងដែរ។ រដ្ឋភាគីគួរបង្កើតនិងអនុម័តបទប្បញ្ញត្តិច្បាប់ ដើម្បីអនុវត្តមាត្រា ៣ នៃអនុសញ្ញានេះដើម្បីដាក់បញ្ចូលទៅក្នុងច្បាប់ជាតិ។ ទោះក្នុងកាលៈទេសៈណាក៏ដោយ រដ្ឋភាគីមិនត្រូវបណ្ដេញចេញ បញ្ជូនត្រឡប់ ឬធ្វើបត្យាប័នបុគ្គលណាមួយទៅកាន់រដ្ឋមួយផ្សេងទៀត នៅពេលមានមូលដ្ឋានគ្រប់គ្រាន់អាចជឿជាក់បានថា ជននោះនឹងស្ថិតក្នុងគ្រោះថ្នាក់នៃការធ្វើទារុណកម្ម ឬប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន។ គណៈកម្មាធិការស្នើសុំឲ្យរដ្ឋភាគីធានាឲ្យមានការតាមដានសមស្រប ពាក់ព័ន្ធនឹងស្ថានភាពនៃអ្នកសុំសិទ្ធិជ្រកកោនជាម៉ុងតាញ៉ាចំនួន ៦៧៤ នាក់ និងអ្នកសុំសិទ្ធិជ្រកកោនជនជាតិអ៊ុយហ្គួចំនួន ២០ នាក់ និងផ្ដល់ព័ត៌មានពីករណីទាំងនេះដល់គណៈកម្មាធិការ។

## ការបណ្ដុះបណ្ដាល

២៥.គណៈកម្មាធិការកត់សំគាល់នូវព័ត៌មានក្នុងរបាយការណ៍រដ្ឋភាគី ស្ដីពីកម្មវិធីបណ្ដុះបណ្ដាល និងលើកកម្ពស់ការយល់ដឹងស្ដីពីសិទ្ធិមនុស្ស សំរាប់មន្ត្រីប្រតិបត្តិច្បាប់រួមមានប៉ូលិស នគរបាលយុត្តិធម៌ ថៅក្រម និងព្រះរាជអាជ្ញា។ ទោះយ៉ាងនេះក្ដី គណៈកម្មាធិការមានការសោកស្ដាយចំពោះការខ្វះខាតព័ត៌មាន ស្ដីពីការបណ្ដុះបណ្ដាលឲ្យចំគោលដៅ និងជាក់ស្ដែងទាក់ទងនឹងកាតព្វកិច្ច ដោយអនុលោមតាមអនុសញ្ញា

ជាពិសេសការហាមឃាត់មិនឲ្យមានការធ្វើទារុណកម្ម ការទប់ស្កាត់ការធ្វើទារុណកម្ម ឬការស៊ើបអង្កេតលើករណីចោទប្រកាន់ថាមានការធ្វើទារុណកម្ម ដូចជាអំពើហិង្សាផ្លូវភេទលើក្រុមទាំងនេះ រួមទាំងបុគ្គលិកពន្ធនាគារផងដែរ។ គណៈកម្មាធិការក៏សម្តែងការសោកស្តាយផងដែរ ចំពោះការខ្វះខាតព័ត៌មានស្តីពីការបណ្តុះបណ្តាលសម្រាប់នគរបាល និងមន្ត្រីពាក់ព័ន្ធផ្សេងៗទៀតក្នុងការធ្វើសម្ភាសសាក្សី ការការពារសាក្សី វិធីសាស្រ្តធ្វើកោសលវិច័យ និងការប្រមូលភស្តុតាង។ ពិសេសជាងនេះទៅទៀត គណៈកម្មាធិការមានការបារម្ភចំពោះការខ្វះខាតព័ត៌មាន ស្តីពីការបណ្តុះបណ្តាលឲ្យចំគោលដៅសម្រាប់មន្ត្រីពាក់ព័ន្ធទាំងអស់ ដូចជាគ្រូពេទ្យខាងកោសលវិច័យ គ្រូពេទ្យព្យាបាលជនជាប់ឃុំ រួមមានវិធីសាស្រ្តនានាក្នុងការចងក្រងឯកសារទាក់ទងនឹងផលប៉ះពាល់ខាងរាងកាយ និងផ្លូវចិត្តដោយសារអំពើទារុណកម្ម ព្រមទាំងវិធីសាស្រ្តក្នុងការធានាឲ្យមានការព្យាបាលសុខភាព និងការឆ្លើយតបផ្លូវច្បាប់។ គណៈកម្មាធិការក៏មានក្តីបារម្ភផងដែរចំពោះការខ្វះខាតព័ត៌មានថាតើក្រមសីលធម៌វិជ្ជាជីវៈ បង្កើតបានជាផ្នែកមួយនៃការបណ្តុះបណ្តាល ឬក៏ក្រមសីលធម៌ទាំងនេះ មានបញ្ចូលការហាមឃាត់លើការធ្វើទារុណកម្មដែរ ឬយ៉ាងណានោះ។ល។ (មាត្រា ១០)។

ដោយមានសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល រដ្ឋភាគីគួរបង្កើត និងពង្រឹងកម្មវិធីអប់រំបន្ថែម ដើម្បីធានាថារាល់មន្ត្រីទាំងអស់មានមន្ត្រីប្រតិបត្តិច្បាប់ និងមន្ត្រីពន្ធនាគារត្រូវយល់ដឹងជ្រៅជ្រះពីបទប្បញ្ញត្តិនៃអនុសញ្ញា ហើយនឹងធ្វើការស៊ើបអង្កេតដោយគ្មានអនុគ្រោះនៅពេលមានរបាយការណ៍ស្តីពីការរំលោភបំពាន រួមមានករណីអំពើហិង្សាផ្លូវភេទជាដើម ដើម្បីឲ្យជនល្មើសទាំងនោះទទួលការកាត់ទោសតាមផ្លូវច្បាប់។ បន្ថែមពីនេះទៀតនគរបាល និងមន្ត្រីពាក់ព័ន្ធផ្សេងៗទៀតគួរទទួលបានការបណ្តុះបណ្តាលក្នុងការសម្ភាសជាមួយសាក្សី ការការពារសាក្សី វិធីសាស្រ្តនីតិវេជ្ជវិទ្យា និងការប្រមូលភស្តុតាង ហើយបុគ្គលិកជាប់ពាក់ព័ន្ធទាំងអស់គួរទទួលបានការបណ្តុះបណ្តាលជាក់លាក់ ស្តីពីរបៀបកំណត់សញ្ញានៃការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន រួមមានមន្ត្រីដែលនឹងធ្វើការស៊ើបអង្កេតនិងចងក្រងឯកសារទាក់ទងនឹងករណីទាំងនេះ។ ការបណ្តុះបណ្តាលនេះគួរមានបញ្ចូលការប្រើប្រាស់សៀវភៅក្បួនស្តីពីការស៊ើបអង្កេត និងការចងក្រងឯកសារប្រកបដោយប្រសិទ្ធភាពទាក់ទងនឹងទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប (ពិធីសា Istanbul)។ បន្ថែមពីនេះទៀត រដ្ឋភាគីគួរធានាថាក្រមសីលធម៌វិជ្ជាជីវៈដែលពាក់ព័ន្ធ និងសារៈសំខាន់ក្នុងការគោរពក្រមសីលធម៌ទាំងនេះ ត្រូវតែធ្វើ

ឲ្យទៅជាផ្នែកចាំបាច់មួយសំរាប់សកម្មភាពបណ្តុះបណ្តាល។ បន្ថែមពីនេះ រដ្ឋភាគីគួរវាយតម្លៃពីប្រសិទ្ធភាព និងផលប៉ះពាល់នៃកម្មវិធីបណ្តុះបណ្តាល/កម្មវិធីអប់រំ។

ដំណោះស្រាយជាប្រាក់សំណង និងការស្តារនីតិសម្បទា

២៦.ទោះបីកត់សំគាល់ឃើញថាមាត្រា ៣៩ នៃរដ្ឋធម្មនុញ្ញ ផ្តល់សិទ្ធិឲ្យប្រជាពលរដ្ឋប្តឹងទារសំណងជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនេះក៏ដោយ ក៏គណៈកម្មាធិការមានក្តីបារម្ភចំពោះការខ្វះខាតព័ត៌មាន និងទិន្នន័យស្តីពីប្រាក់សំណងដ៏ត្រឹមត្រូវ និងគ្រប់គ្រាន់សម្រាប់ជនរងគ្រោះពីការធ្វើទារុណកម្ម។ គណៈកម្មាធិការក៏មានការព្រួយបារម្ភផងដែរចំពោះការខ្វះខាតព័ត៌មានស្តីពីការផ្តល់សេវាព្យាបាល និងសេវាស្តារនីតិសម្បទាសង្គម រួមមានការស្តារនីតិសម្បទាខាងវេជ្ជសាស្ត្រ និងការស្តារនីតិសម្បទាផ្លូវចិត្ត សម្រាប់ជនរងគ្រោះទាំងអស់ពីការធ្វើទារុណកម្ម (មាត្រា ១៤)។

គណៈកម្មាធិការលើកឡើងថា រដ្ឋភាគីគឺជាអ្នកទទួលខុសត្រូវលើការផ្តល់សំណងដល់ប្រជាពលរដ្ឋរងគ្រោះពីការធ្វើទារុណកម្ម និងក្រុមគ្រួសាររបស់ពួកគេ។ ដើម្បីសម្រេចគោលបំណងនេះ រដ្ឋភាគីគួរបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីឲ្យប្រជាពលរដ្ឋរងគ្រោះពីការធ្វើទារុណកម្ម ទទួលបានសំណង រួមមានប្រាក់សំណងដែលត្រឹមត្រូវ និងគ្រប់គ្រាន់ និងការស្តារនីតិសម្បទាឲ្យបានពេញលេញតាមដែលអាចធ្វើបាន។ រដ្ឋភាគីគួរបង្កើនកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីកែលំអលទ្ធភាពទទួលបានសេវាខាងវេជ្ជសាស្ត្រ និងសេវាខាងផ្លូវចិត្តសម្រាប់ប្រជាពលរដ្ឋរងគ្រោះពីការធ្វើទារុណកម្ម ជាពិសេសក្នុងអំឡុងពេល និងបន្ទាប់ពីការជាប់ឃុំក្នុងពន្ធនាគារ ហើយធានាថាជនរងគ្រោះទាំងនោះ ទទួលបានសេវាស្តារនីតិសម្បទាដែលមានប្រសិទ្ធភាព និងបន្ទាន់ ដើម្បីលើកកម្ពស់ការយល់ដឹងពីផលវិបាកនៃទារុណកម្ម និងតម្រូវការការស្តារនីតិសម្បទាសម្រាប់ជនរងគ្រោះពីការធ្វើទារុណកម្ម ក្នុងចំណោមអ្នកជំនាញខាងសុខភាព និងអ្នកជំនាញខាងសុខុមាលភាពសង្គម និងដើម្បីបង្កើនការបញ្ជូនជនរងគ្រោះទាំងនេះពីប្រព័ន្ធថែទាំសុខភាពកម្រិតបឋម ទៅកាន់សេវាឯកទេសជំនួសវិញ និងដើម្បីបង្កើនសមត្ថភាពទីភ្នាក់ងារសុខភាពជាតិឲ្យផ្តល់សេវាស្តារនីតិសម្បទាឯកទេស ផ្អែកលើបទដ្ឋានអន្តរជាតិបែបអនុសាសន៍ ដល់ប្រជាពលរដ្ឋរងគ្រោះពីការធ្វើទារុណកម្ម រួមទាំងសមាជិកក្រុមគ្រួសាររបស់ពួកគេ ជាពិសេសក្នុងវិស័យសុខភាពផ្លូវចិត្ត ។

២៧.គណៈកម្មាធិការមានក្តីបារម្ភថាវិធាននៃផ្ទៃក្នុង សម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ផ្តល់ត្រឹមតែសំណងផ្លូវចិត្តនិងសំណងជាសមូហភាពតែប៉ុណ្ណោះ ដោយមិនគិតពីសំណងជាទឹកប្រាក់សំរាប់បុគ្គលឡើយ។ ទោះបីកត់សំគាល់ឃើញមានអង្គភាពគាំពារជនរងគ្រោះក៏ដោយ ក៏គណៈកម្មាធិការមានការព្រួយបារម្ភថា ការស្តារនីតិសម្បទា និងការគាំទ្រខាងចិត្តសាស្ត្រសម្រាប់ជនរងគ្រោះជាសាក្សីទាំងនោះក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ភាគច្រើនទទួលបានតាមរយៈអង្គការមិនមែនរដ្ឋាភិបាល ការគាំទ្របែបនេះទទួលបានពីរដ្ឋមានកំរិត ហើយគណៈកម្មាធិការមានការសោកស្តាយចំពោះការខ្វះខាតព័ត៌មានស្តីពីសេវាព្យាបាល និងការស្តារនីតិសម្បទាសង្គម រួមមានការស្តារនីតិសម្បទាខាងវេជ្ជសាស្ត្រ និងខាងចិត្តសាស្ត្រសម្រាប់ជនរងគ្រោះពីការធ្វើទារុណកម្មក្នុងរបបខ្មែរក្រហម(មាត្រា១៤)។

រដ្ឋភាគីគួរបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីឲ្យជនរងគ្រោះពីការធ្វើទារុណកម្មក្នុងរបបខ្មែរក្រហម ទទួលបានសំណងរួមមានសំណងត្រឹមត្រូវ និងគ្រប់គ្រាន់និងការស្តារនីតិសម្បទាឲ្យបានពេញលេញតាមដែលអាចធ្វើបាន។ ដើម្បីសម្រេចគោលបំណងនេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវកែប្រែវិធាននៃផ្ទៃក្នុងរបស់ខ្លួនដើម្បីឲ្យជនរងគ្រោះពីការធ្វើទារុណកម្ម ទទួលបានសំណងដោយអនុលោមទៅតាមមាត្រា១៤ នៃអនុសញ្ញា រួមមានសំណងជាទឹកប្រាក់សមរម្យសំរាប់បុគ្គល។ ពិសេសជាងនេះទៅទៀត រដ្ឋភាគីគួរផ្តល់ព័ត៌មានស្តីពីវិធានការដោះស្រាយ និងសំណងដែលបង្គាប់ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់ជនរងគ្រោះពីការធ្វើទារុណកម្ម ឬសំរាប់ក្រុមគ្រួសាររបស់ពួកគេ។ ព័ត៌មានទាំងនេះត្រូវរួមបញ្ចូលចំនួនសំណើដែលបានលើកឡើង ចំនួនវិធានការសំណងដែលបានផ្តល់ និងចំនួនទឹកប្រាក់ដែលបង្គាប់ ហើយនិងផ្តល់ឲ្យក្នុងករណីនីមួយៗ។

## ចម្លើយសារភាពដោយបង្ខំ

២៨.គណៈកម្មាធិការលើកឡើងពីក្តីបារម្ភរបស់ខ្លួនក្នុងរបាយការណ៍ដែលថា ការប្រើប្រាស់ចម្លើយសារភាពដោយបង្ខំសម្រាប់ជាភស្តុតាងក្នុងតុលាការ កើតមានជាទូទៅនៅក្នុងរដ្ឋភាគី។ គណៈកម្មាធិការក៏មានក្តីបារម្ភចំពោះការខ្វះខាតព័ត៌មាន ស្តីពីមន្ត្រីដែលអាចធ្វើការចោទប្រកាន់ ឬត្រូវបានផ្តន្ទាទោសពីបទជំរិតយកចម្លើយសារភាពបែបនេះ (មាត្រា ១ មាត្រា ២ មាត្រា ៤ មាត្រា ១០ និងមាត្រា ១៥)។

រដ្ឋភាគីគួរចាត់វិធានការចាំបាច់ដើម្បីធានាថា នៅក្នុងតុលាការមិនត្រូវទទួលយកចម្លើយសារភាព ដែលបានពីការធ្វើទារុណកម្មនៅគ្រប់ករណីទាំងអស់ ដោយអនុលោមទៅតាមបទប្បញ្ញត្តិមាត្រា ១៥ នៃអនុសញ្ញានេះ។ គណៈកម្មាធិការស្នើសុំឲ្យរដ្ឋភាគីប្រកាន់គោលជំហររឹងមាំមិនទទួលយកភស្តុតាងបានមកពីការធ្វើទារុណកម្មនៅគ្រប់ចំណាត់ការនីតិវិធី និងផ្តល់ព័ត៌មានស្តីពីថាតើមានមន្ត្រីណាខ្លះត្រូវបានធ្វើការចោទប្រកាន់ និងផ្តន្ទាទោសពីបទជំរិតយកចម្លើយសារភាពបែបនេះ ព្រមទាំងការផ្តល់ឧទាហរណ៍នូវករណីទាំងឡាយ ដែលជំកល់ទុកឥតចាត់ការពីបទបង្ខិតបង្ខំឲ្យផ្តល់ចម្លើយសារភាព។ ពិសេសជាងនេះទៅទៀត រដ្ឋភាគីគួរធានាឲ្យមានការណ្តុះបណ្តាលដល់មន្ត្រីប្រតិបត្តិច្បាប់ ចៅក្រម និងមេធាវីស្តីពីការកំណត់អត្តសញ្ញាណ និងការស៊ើបអង្កេតលើចម្លើយសារភាពដោយបង្ខំ។

## ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ

២៩.គណៈកម្មាធិការកត់សំគាល់ដោយក្តីបារម្ភដែលថា រដ្ឋភាគីមិនមានស្ថាប័នសិទ្ធិមនុស្សឯករាជ្យថ្នាក់ជាតិ ដែលគោរពទៅតាមគោលការណ៍ទីក្រុងប៉ារីស (សេចក្តីសំរេចរបស់មហាសន្និបាត ៤៨/១៣៤ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ ១៩៩៣) (មាត្រា ២)។

រដ្ឋភាគីគួរពន្លឿនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការបង្កើតស្ថាប័នសិទ្ធិមនុស្សឯករាជ្យថ្នាក់ជាតិមួយ ដែលគោរពទៅតាមគោលការណ៍ទីក្រុងប៉ារីស។ គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីធ្វើការធានាថា ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិដែលនឹងបង្កើតនេះ គឺត្រូវមានអាណត្តការងារដើម្បីការពារ និងលើកកម្ពស់បទប្បញ្ញត្តិនៃអនុសញ្ញាស្តីពីសិទ្ធិមនុស្ស និងទទួលបានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការឯករាជ្យដោយខ្លួនឯង។ ទាក់ទងនឹងបញ្ហានេះ រដ្ឋភាគីគួរស្វែងរកជំនួយបច្ចេកទេសពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា។

## យន្តការបង្ការទារុណកម្មថ្នាក់ជាតិ

៣០.គណៈកម្មាធិការកត់សំគាល់នូវការបង្កើតគណៈកម្មាធិការអន្តររដ្ឋាភិបាលតាមរយៈអនុក្រឹត្យនៅខែសីហា ឆ្នាំ២០០៩ ដែលជាស្ថាប័នបណ្តោះអាសន្នមួយសម្រាប់ឆ្ពោះទៅរកការបង្កើតយន្តការបង្ការទារុណកម្មថ្នាក់ជាតិមួយ (NPM)។ ទោះជាយ៉ាងណាក៏ដោយ គណៈកម្មាធិការកត់សំគាល់ដោយក្តីបារម្ភថា គណៈកម្មាធិការអន្តររដ្ឋាភិបាលដែលមានមន្ត្រីជាន់ខ្ពស់ និងមានប្រធានជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃនេះ មិនគោរពទៅតាមលក្ខខណ្ឌតម្រូវនៃពិធីសារបន្ថែមទៅលើអនុ

សញ្ញាប្រឆាំងទារុណកម្ម ជាពិសេសទាក់ទងនឹងឯករាជ្យភាពរបស់ខ្លួន និងមិនមានការចូលរួមពីសង្គមស៊ីវិលឡើយ។ គណៈកម្មាធិការក៏មានក្តីបារម្ភផងដែរចំពោះព័ត៌មាន ទទួលបានពីគណៈប្រតិភូដែលថា អាណត្តិការងារនៃយន្តការបង្ការទារុណកម្មថ្នាក់ជាតិបច្ចុប្បន្ននេះ មិនបានផ្តល់ឲ្យមានដំណើរទស្សនកិច្ចត្រួតពិនិត្យដោយមិនប្រកាសឲ្យដឹងជាមុននោះទេ (មាត្រា ២)។

រដ្ឋភាគីគួរចាត់វិធានការចាំបាច់ទាំងអស់ដើម្បីធានាថា យន្តការបង្ការទារុណកម្មថ្នាក់ជាតិនឹងត្រូវបង្កើតឡើងដោយគោរពទៅតាមពិធីសារបន្ថែមទៅលើអនុសញ្ញាប្រឆាំងទារុណកម្ម។ ដើម្បីសម្រេចគោលបំណងនេះ រដ្ឋភាគីគួរធានាថាយន្តការបង្ការទារុណកម្មថ្នាក់ជាតិនេះ នឹងត្រូវបង្កើតឡើងតាមរយៈការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ឬតាមច្បាប់រៀបចំអង្គការ ហើយយន្តការនេះត្រូវតែជាយន្តការដែលមានវិជ្ជាជីវៈ និងឯករាជ្យទាំងខាងស្ថាប័ន និងទាំងហិរញ្ញវត្ថុ។ រដ្ឋភាគីគួរធានាផងដែរថាច្បាប់ដែលបង្កើតយន្តការបង្ការទារុណកម្មថ្នាក់ជាតិ នឹងត្រូវកំណត់ឲ្យបានច្បាស់លាស់ថា យន្តការនេះនឹងត្រូវមានសមត្ថភាពធ្វើទស្សនកិច្ចត្រួតពិនិត្យដោយមិនប្រកាសឲ្យដឹងជាមុនទៅគ្រប់ទីកន្លែងទាំងអស់ ដែលមនុស្សនៅទីកន្លែងទាំងនោះត្រូវបាន ឬអាចត្រូវបានគេដកហូតសិទ្ធិសេរីភាព និងធ្វើបទសម្ភាសន៍ជាសម្ងាត់ជាមួយអ្នកទាំងនោះ ហើយច្បាប់នេះនឹងមានចែងអំពីនីតិវិធីជ្រើសរើសដោយតម្លាភាព ក្នុងគោលដៅតែងតាំងសមាជិកឯករាជ្យសម្រាប់ស្ថាប័ននេះ។

គណៈកម្មាធិការជំរុញឲ្យរដ្ឋភាគគីពិចារណា លើការចេញផ្សាយរបាយការណ៍របស់អនុគណៈកម្មាធិការបង្ការទារុណកម្ម បន្ទាប់ពីបានបំពេញទស្សនកិច្ចត្រួតពិនិត្យរបស់ខ្លួននៅខែធ្នូ ឆ្នាំ ២០០៩។

## កិច្ចសហការជាមួយអង្គការសង្គមស៊ីវិល

៣១.ទោះបីជារដ្ឋភាគីសង្កត់ធ្ងន់ទៅលើការងារក្នុងការសហការជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលក៏ដោយ ក៏គណៈកម្មាធិការមានក្តីបារម្ភចំពោះការខ្វះខាតព័ត៌មានដែលថាតើសេចក្តីព្រាងច្បាប់សម្រាប់គ្រប់គ្រងអង្គការសង្គមស៊ីវិល អាចរារាំងដល់ដំណើរការ និងសកម្មភាពរបស់ក្រុមឃ្លាំមើលរបស់សង្គមស៊ីវិល និងសមត្ថភាពរបស់ពួកគេក្នុងការបំពេញមុខងារប្រកបដោយប្រសិទ្ធភាពដែរ ឬយ៉ាងណានោះទេ រួមមានអង្គការមិនមែនរដ្ឋាភិបាលដែលបំពេញការងារដើម្បីទប់ស្កាត់ និងប្រយុទ្ធ

ប្រឆាំងការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន (មាត្រា ២ មាត្រា ១១ មាត្រា ១២ និងមាត្រា ១៣)។

រដ្ឋភាគីគួរធានាថាអង្គការសង្គមស៊ីវិល រួមមានអង្គការមិនមែនរដ្ឋាភិបាល មិនត្រូវទទួលរងការដាក់កំហិតពាក់ព័ន្ធនឹងការបង្កើត និងដំណើរការរបស់ពួកគេទេ ហើយអង្គការទាំងនេះអាចដំណើរការដោយឯករាជ្យពីរដ្ឋាភិបាល។ ជាពិសេសគណៈកម្មាធិការជំរុញឲ្យរដ្ឋភាគីផ្តល់បរិយាកាសអំណោយផលសម្រាប់ការបង្កើត និងការចូលរួមយ៉ាងសកម្មរបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងការលើកកម្ពស់ការអនុវត្តអនុសញ្ញានេះ។

## ការប្រមូលទិន្នន័យ

៣២.ទោះបីគណៈកម្មាធិការស្នើសុំព័ត៌មានស្ថិតិជាក់លាក់ក្នុងបញ្ជីសំណួរមុនពេលធ្វើរបាយការណ៍ និងកិច្ចសន្ទនាផ្ទាល់មាត់ជាមួយរដ្ឋភាគីក៏ដោយ ក៏គណៈកម្មាធិការមានការសោកស្តាយដែលថា ព័ត៌មានទាំងនេះមិនត្រូវបានផ្តល់ឲ្យនោះទេ។ ការមិនទទួលបានទិន្នន័យរួម ឬទិន្នន័យដោយឡែកៗស្តីពីការប្តឹងតវ៉ា ការស៊ើបអង្កេត ការចោទប្រកាន់ និងការផ្តន្ទាទោសលើករណីធ្វើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួនដោយមន្ត្រីប្រតិបត្តិច្បាប់ និងមន្ត្រីពន្ធនាគារ ការជួញដូរ អំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទ រារាំងដល់ការកំណត់បទរំលោភបំពានជាច្រើន ដែលទាមទារឲ្យមានការយកចិត្តទុកដាក់ (មាត្រា ២ មាត្រា ១២ មាត្រា ១៣ និងមាត្រា ១៩)។

រដ្ឋភាគីគួរប្រមូលទិន្នន័យស្ថិតិពាក់ព័ន្ធនឹងការឃ្លាំមើលការអនុវត្តអនុសញ្ញានៅថ្នាក់ជាតិដែលទិន្នន័យបែងចែកតាមយេនឌ័រ អាយុ សញ្ជាតិ ព្រមទាំងព័ត៌មានស្តីពីការប្តឹងតវ៉ា ការស៊ើបអង្កេត ការចោទប្រកាន់ និងការផ្តន្ទាទោសលើករណីធ្វើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន ការជួញដូរ អំពើហិង្សាក្នុងគ្រួសារ និងផ្លូវភេទ និងលទ្ធផលបណ្តឹងតវ៉ា និងករណីទាំងអស់នេះ។ រដ្ឋភាគីគួរផ្តល់ព័ត៌មានលំអិតដែលរៀបរាប់ខាងលើជាបន្ទាន់ដល់គណៈកម្មាធិការរួមមានចំនួនបណ្តឹងតវ៉ាលើការធ្វើទារុណកម្ម ការបំពារបំពាន និងប្រព្រឹត្តកម្មមិនគប្បីផ្សេងៗទៀត ដែលបានបញ្ជូនមកតាំងពីឆ្នាំ២០០៣ កាលបរិច្ឆេទនៃការពិនិត្យពិចារណាលើរបាយការណ៍របស់រដ្ឋភាគីពីមុនមក ព្រមទាំងចំនួនការស៊ើបអង្កេត ការចោទប្រកាន់ និងការផ្តន្ទាទោសដែលកើតមានពីបណ្តឹងតវ៉ាទាំងនេះ។

៣៣.គណៈកម្មាធិការលើកអនុសាសន៍ស្នើឲ្យរដ្ឋភាគី ពិចារណាលើការធ្វើសេចក្តីប្រកាស អនុលោមតាមមាត្រា ២១ និងមាត្រា ២២ នៃអនុសញ្ញា។

៣៤.គណៈកម្មាធិការស្នើសុំអញ្ជើញរដ្ឋភាគី ពិចារណាលើការផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗរបស់អង្គការសហប្រជាជាតិ ដែលប្រទេសកម្ពុជាមិនទាន់ចូលជាភាគី ជាពិសេសអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ អនុសញ្ញាស្តីពីសិទ្ធិជនពិការ និងអនុសញ្ញាអន្តរជាតិស្តីពីការការពារមនុស្សទាំងអស់ពីការបាត់ខ្លួនដោយបង្ខំ។

៣៥.រដ្ឋភាគីទទួលបានការលើកទឹកចិត្តឲ្យផ្សព្វផ្សាយរបាយការណ៍នានា ដែលកម្ពុជាបញ្ជូនមកគណៈកម្មាធិការឲ្យបានទូលំទូលាយ ហើយនឹងសេចក្តីសង្កេតសន្និដ្ឋានទាំងនេះជាភាសាសមស្រប តាមរយៈគេហទំព័រផ្លូវការ ប្រព័ន្ធផ្សព្វផ្សាយ និងអង្គការមិនមែនរដ្ឋាភិបាល។

៣៦.គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីផ្តល់ព័ត៌មានស្តីពីការឆ្លើយតបរបស់ខ្លួន ទៅនឹងអនុសាសន៍នានារបស់គណៈកម្មាធិការ ដែលមាននៅក្នុងកថាខណ្ឌ ១២ ១៤ ១៦ ២៦ និង២៧ ក្នុងរយៈពេលមួយឆ្នាំ។

៣៧.គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីដាក់ជូននូវរបាយការណ៍បន្ទាប់តាមកាលកំណត់ អនុលោមតាមគោលការណ៍ ស្តីពីការធ្វើរបាយការណ៍របស់ខ្លួន និងគោរពតាមការកំណត់ទំព័រចំនួន ៤០ ទំព័រសម្រាប់ឯកសារជាក់លាក់តាមសន្ធិសញ្ញានិមួយៗ។ គណៈកម្មាធិការក៏ស្នើឲ្យរដ្ឋភាគីដាក់ជូនឯកសារគោលរួម ដែលធ្វើបច្ចុប្បន្នភាពស្របតាមលក្ខខណ្ឌតម្រូវឯកសារគោលរួម ដែលមាននៅក្នុងគោលការណ៍ណែនាំស្របគ្នាស្តីពីការធ្វើរបាយការណ៍ អនុលោមតាមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ (HRI/GEN.2/Rev.6) ដែលអនុម័តដោយកិច្ចប្រជុំអន្តរគណៈកម្មាធិការនៃស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ហើយគោរពតាមការកំណត់ទំព័រចំនួន ៨០ ទំព័រសម្រាប់ឯកសារគោលរួម។ ឯកសារជាក់លាក់តាមសន្ធិសញ្ញា និងឯកសារគោលរួមទាំងពីរនេះ បង្កើតឲ្យមានកាតព្វកិច្ចធ្វើរបាយការណ៍របស់រដ្ឋភាគី ដោយអនុលោមតាមអនុសញ្ញា។

៣៨.រដ្ឋភាគីត្រូវបានអញ្ជើញឲ្យដាក់ជូនរបាយការណ៍តាមពេលកំណត់លើកទីបីរបស់ខ្លួននៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៤។